BMI0068

# សម្ភាសន៍ជាមួយឈ្មោះ អែម រ៉េន ភេទប្រុស អាយុ៥៨ឆ្នាំ

មុខងារសម័យខ្មែរក្រហមៈ ទ័ពការពារព្រំដែនរតនគីរី

មុខងារបច្ចុប្បន្នៈ ប្រជាជន

ស្រុកកំណើតនៅភូមិត្នោតលើ ឃុំថ្មក ស្រុកស្អាង ខេត្តកណ្តាល

សព្វថ្ងៃរស់នៅភូមិសង្កែ ឃុំបឹងបេង ស្រុកម៉ាឡៃ ខេត្តបន្ទាយមានជ័យ

ថ្ងៃទី២០ ខែតុលា ឆ្នាំ២០១០

សម្ភាសន៍ដោយៈ ឆាយ ឈុនលី

០១:២០:៥៨

៣៨ទំព័រ

ឈុនលី ៖ ខ្ញុំចង់ដឹងអ៊ំឈ្មោះអី?

រ៉េន ៖ ខ្ញុំឈ្មោះ អែម រ៉េន ។

ឈុនលី ៖ អាយុប៉ុន្មាន?

រ៉េន ៖ អាយុ៥៨ ។

ឈុនលី ៖ អានេះគេហៅភូមិ?

រ៉េន ៖ ភូមិសង្កែ ។

ឈុនលី ៖ អ៊ំមានស្រុកកំណើតនៅណា?

រ៉េន ៖ ស្រុកកំណើតនៅភូមិត្នោតលើ ឃុំថ្មក ស្រុកស្អាង ខេត្តកណ្តាល ។

ឈុនលី ៖ ហេតុអីបានអ៊ំមកដល់ទីនេះតាំងពីឆ្នាំ៧៩?

រ៉េន ៖ អានឹងរត់យួន ពេលយួនចូល៧៩នឹង ខ្ញុំរត់ពីរតនគីរីមកព្រំដែនរតនគីរី ។

ឈុនលី ៖ ហេតុអីបានទៅដល់រតនគីរី?

រ៉េន ៖ ខ្ញុំទៅសម័យ៣ឆ្នាំ ទៅការពារព្រំដែនរតនគីរី ទៅការពារនៅព្រំដែន ។

ឈុនលី ៖ កាលនឹងអ៊ំចូលធ្វើទ័ព?

រ៉េន ៖ ទ័ព ។

ឈុនលី ៖ ចូលតាំងពីពេលណា?

រ៉េន ៖ ខ្ញុំចូលតាំងពី៧០ ១៩៧០ ។

ឈុនលី ៖ កាលនឹងអ៊ំនៅណាឆ្នាំ៧០?

វ៉េន ៖ ឆ្នាំ៧០ នៅស្រុកកំណើត ។

ឈុនលី ៖ ហេតុអីបានចូល?

វ៉េន ៖ ចូលពេលលន់ នល់ធ្វើរដ្ឋប្រហារទម្លាក់សម្តេចសីហនុ ។

ឈុនលី ៖ មានអ្នកណាគេអ្នកនាំឲ្យចូល?

វ៉េន ៖ អត់អ្នកណានាំទេ ខ្ញុំចូលខ្លួនឯង នឹកឃើញថា ពេលនឹងចុះបើសម្តេចលោកអ្នកគ្រប់គ្រង យើងមានតែតស៊ូដើម្បីរំដោះសម្តេចចូលប្រទេសវិញអានឹងគំនិតដែលប៉ុងប្រាថ្នាគឺមានប៉ុននឹង

ឈុនលី ៖ ចុះអ៊ំមានបងប្អូនប៉ុន្មាននាក់?

វ៉េន ៖ បងប្អូនខ្ញុំមាន៨នាក់ តែស្លាប់ពី៧៨ស្លាប់ម្នាក់ប្រុស ។

ឈុនលី ៖ ស្លាប់ដោយសារអីគេ?

វ៉េន ៖ ស្លាប់ធ្វើទ័ពដែរ ។

ឈុនលី ៖ ដល់ពេលឆ្នាំ៧០ ចូលទ័ពទៅនៅណាទៀត?

វ៉េន ៖ អត់ទេ នៅក្នុងតំបន់នឹងនៅខេត្តកណ្តាល ។

ឈុនលី ៖ អានឹងគេហៅអីគេ កង១វរៈ?

វ៉េន ៖ កងវរៈកងពលលេខ១១ ។

ឈុនលី ៖ នៅស្រុកស្អាងនឹង?

វ៉េន ៖ នៅស្អាងនឹងម៉ង ឈរជើងនៅស្អាងនឹង ពីដើមជំនាន់នឹងគេហៅតំបន់២៥ ។

ឈុនលី ៖ នៅខាងស្អាងនឹង?

វ៉េន ៖ ហ្នឹងហើយ អាខេត្តកណ្តាលនឹងយើងពីដើម ប៉ុនដល់សម័យតស៊ូគេដាក់តំបន់២៥ ។

ឈុនលី ៖ ចុះពេលណាបានអ៊ំចេញពីតំបន់នឹងទៅរតនគិរី?

វ៉េន ៖ ចេញពេលរំដោះភ្នំពេញហើយ រំដោះភ្នំពេញខ្ញុំក៏បានរំដោះ ។

ឈុនលី ៖ ៧៥ហ្នឹង?

វ៉េន ៖ បាទ! រំដោះ៧៥នឹង ខ្ញុំបានរំដោះដែរ ខ្ញុំចេញពីថ្នល់ជាតិលេខ៤ ។ ខ្ញុំមកវ៉ៃថ្នល់ជាតិលេខ៤ ៧៤ ។

ឈុនលី ៖ វ៉ៃជាមួយខាងណា?

វ៉េន ៖ វ៉ៃជាមួយលន់ នល់នឹង ដល់វ៉ៃថ្នល់ជាតិលេខ៤ហើយបានចេញទៅទន្លេបាសាក់នឹង បានគេឲ្យវ៉ៃចូលភ្នំពេញនឹងបណ្តោយរំដោះ៧៥នឹង១ក៏ខ្ញុំនៅភ្នំពេញ ។

ឈុនលី ៖ នៅណាវិញ នៅម៉ុំណា?

វ៉ន ៖ នៅផ្សារដើមគរ មុខសញ្ញាខ្ញុំការពារពីផ្សារដើមគរទៅស្ពានអូរឡាំពិចនឹងទៅទល់ពេទ្យចិន ពេទ្យរុស្ស៊ីនឹង ដូវនឹងមុខសញ្ញាខ្ញុំការពារ ។

ឈុនលី ៖ ការនឹងអ្នកណាគេ អ្នកដឹកនាំឲ្យការពារ?

វ៉ន ៖ ប៉ុលពត ជំនាន់ប៉ុលពតកាន់អំណាច ។

ឈុនលី ៖ អ៊ំដែលឃើញមុខគាត់ពេលនឹង?

វ៉ន ៖ អត់ដែលឃើញផង ឮតែឈ្មោះ បើអ៊ំខៀវ សំផន, អ៊ំហ៊ូ នឹម, ហ៊ូ យន់ អានឹងខ្ញុំឃើញ ខ្ញុំស្គាល់ ។

ឈុនលី ៖ ឃើញពេលណា?

វ៉ន ៖ ឃើញនៅពេលរំដោះ៧៥នឹង គាត់ទៅទទួលសម្តេចចូលប្រទេស ។

ឈុនលី ៖ ទទួលនៅពេលណា?

វ៉ន ៖ ទទួលនៅពោធិ៍ចិនតុង អានឹងគាត់ទៅយានង ។

ឈុនលី ៖ ហើយអ៊ំទៅដែរ?

វ៉ន ៖ ខ្ញុំទៅចុះទ័ពការពារនឹង ទៅទទួលសម្តេច ។

ឈុនលី ៖ ចុះបន្ទាប់មកទៀត ម៉េចបានអ៊ំបានទៅដល់ណា?

វ៉ន ៖ កាលនឹង កាលគេបញ្ជូនទៅខែ១២ ៧៥នឹងគេបញ្ជូនទៅការពារព្រំដែននៅរតនគិរី ។

ឈុនលី ៖ ចុះពេលអ៊ំនៅផ្សារដើមគរនឹង នៅឆ្នាំ?

វ៉ន ៖ អានឹងពេលគេរំដោះហើយ រំដោះភ្លាម អាពេលរំដោះនឹងឈរការពារនៅនឹង ដល់គេរៀបចំកងការពារព្រំដែនបានគេបញ្ជូនកងខ្ញុំទៅការពារនៅខេត្តរតនគិរី ។

ឈុនលី ៖ នៅស្រុកអីគេ?

វ៉ន ៖ នៅបរកែវ បាលុង សៀមបាំង ។

ឈុនលី ៖ ដូវគ្រប់ស្រុក?

វ៉ន ៖ ហ្នឹងហើយ ។

ឈុនលី ៖ អានឹងយើងការពារជាមួយពួកខាងណា?

វ៉ន ៖ ការពារវៀតណាម យើងខាងខ្មែរការពារដីខ្មែរជាមួយព្រំប្រទល់វៀតណាមនោះ ។

ឈុនលី ៖ បានន័យថាអ៊ំចូលក្នុងកងវរៈណាផ្សេងទៀត?

វ៉ន ៖ ហ្នឹងអានឹងរំលាយៗកងពល១១ចូលក្នុងកងពល១៨ គេបញ្ជូនទៅខេត្តរតនគិរី អានឹងកងថ្មីហើយ ។

ឈុនលី ៖ អ្នកណាគេអ្នកគ្រប់គ្រងកង?

វ៉ន ៖ ហ្នឹងសូរសារឿន កងពល ឥឡូវស្លាប់អស់ហើយ ស្លាប់កាលផ្តាច់ខ្លួន ស្លាប់នៅអូរសំព័រ១ នៅខត្តរ ។

ឈុនលី ៖ បើគិតទៅអ្នកណាគេអ្នកគ្រប់គ្រងនៅរតនគីរីនឹង?

វ៉ន ៖ រតនគីរីនឹង យើងខាងយោធាយើងនិយាយខាងយោធា បើខាងមូលដ្ឋាននឹងមានគណៈតំបន់គេផ្សេង គេគ្រប់គ្រងខាងមូលដ្ឋាន ។

ឈុនលី ៖ អានឹងគេហៅតំបន់អីខាងប៉ែកខាងនឹង?

វ៉ន ៖ ហៅរតនគីរីហ្នឹងម៉ង អានឹងហៅភូមិភាគអីគេ ភូមិភាគឥសានកាលជំនាន់នឹងខាងរតនគីរីនឹង ។

ឈុនលី ៖ ហើយកាលនឹងលំបាកទេ?

វ៉ន ៖ លំបាក ចុះយើងលំបាកហើយ ទៅដល់ខ្ញុំនិយាយពីជំនាន់នេះវិញ សួអត់មាននេះទេមានតែប្រហុកហើយនឹងគល់ចេកព្រៃអំបិលបង់ប្រែៗកងទ័ពលើភ្នំស្រែផងអីផង ការពារ ។

ឈុនលី ៖ កងទ័ពនឹងធ្វើស្រែទៀត?

វ៉ន ៖ ធ្វើស្រែលើកភ្នំ ប៉ុលពតឲ្យលើកភ្នំទាំងអស់ ហើយបាយឲ្យស៊ីតែម៉ាកំប៉ុងកន្ទះទេក្នុងមួយថ្ងៃៗព្រឹកកាចអត់ដល់ម៉ាកំប៉ុងទេ អានឹងម៉ាពេល ។ ហើយបើអាណាធ្វើខុស បាយក្នុងម៉ាពេលនឹងគឺដកពុះជា២ចែកឲ្យអ្នកធ្វើយើងអ្នកកំហុសនឹងបានតែពាក់កណ្តាល ។

ឈុនលី ៖ ចុះអ៊ំធ្លាប់ធ្វើខុស?

វ៉ន ៖ ខ្ញុំខុសដែលនឹង ។

ឈុនលី ៖ រឿងអី?

វ៉ន ៖ ខ្ញុំរឿងអត់សូវចេះស្តាប់មេ ។

ឈុនលី ៖ ម៉េចអត់?

វ៉ន ៖ តែមេធ្វើមិនស្រួលអត់ស្តាប់ម៉ង ។

ឈុនលី ៖ មេណា?

វ៉ន ៖ មេថ្មីមេកងពល វរសេនាធំកែវសារឿន កងពលសូ សារឿនៗជំនិតដៃស្តាំរបស់ប៉ុលពតផ្ទាល់ ។

ឈុនលី ៖ សូ សារឿនជំនិតដៃស្តាំតាំងពីជំនាន់នឹង?

វ៉ន ៖ ហ្នឹងហើយជំនាន់នឹងម៉ង ។

ឈុនលី ៖ ឥឡូវគាត់នៅណា?

វ៉ន ៖ ឥឡូវស្លាប់បាត់ហើយ ស្លាប់នៅអន្លង់វែងម៉ាហឹកផ្តាច់ខ្លួននឹង ។

ឈុនលី ៖ ដោយសារអីគេ?

វ៉ែន ៖ ដោយសារគ្នាឯង ចុះដឹងស្រាប់ហើយដូចនៅម៉ាឡែផ្ដាច់ខ្លួនមិនសុន សេនរឺបលោកសុខ ភាព និងអ៊ី ឈាន។ ប៉ុនបានអ៊ី ឈាន ហើយនឹងលោកសុខ ភាព សាមគ្គីគ្នារួមកងទ័ពរួមប្រជាជន សុន សេនធ្វើអត់បាន។

ឈុនលី ៖ ម៉េចខ្លះអ៊ំ?

វ៉ែន ៖ ម៉េចសុន សេន គាត់ចង់ធ្វើកុម្មុយនីសលើកទី២ ។

ឈុនលី ៖ អានឹងឆ្នាំណា?

វ៉ែន ៖ ឆ្នាំផ្ដាច់ខ្លួននឹង ឆ្នាំ៩០ប៉ុន្មានដែលថាយើងផ្ដាច់ខ្លួន។

ឈុនលី ៖ ៩៦?

វ៉ែន ៖ ទេ! មិនមែន៩៦ ។

ឈុនលី ៖ មុននឹងទៀត?

វ៉ែន ៖ ៩៣ ចុះអ៊ុនតាក់ចូល៩០ប៉ុន្មាន។

ឈុនលី ៖ ខ្ទង់៩២ ៩៣?

វ៉ែន ៖ ខ្ញុំអត់ចាំ ។

ឈុនលី ៖ អ៊ុនតាក់ចូលខ្ទង់៩២ ៨៣ តាមពិតអ៊ុនតាក់ចូលតាំងពី៩១ តែនៅរហូតដល់៩៣យើងបោះឆ្នោត?

វ៉ែន ៖ បោះឆ្នោតយើងមិនដឹងប៉ុន្មាន ខ្ញុំអត់ចាំដែរ ។

ឈុនលី ៖ តែពេលនឹងអ៊ុនតាក់ចូលឬនៅ?

វ៉ែន ៖ ចូលហើយផ្ដាច់ខ្លួន អ៊ុនតាក់ចូលហើយគេហៅបង្កើតរដ្ឋាភិបាលចំរុះ ។

ឈុនលី ៖ ពេលផ្ដាច់ខ្លួនពេលសម្ដេចហ៊ុន សែន គាត់យាងមកនឹង?

វ៉ែន ៖ ហ្នឹងហើយ ។

ឈុនលី ៖ អានឹងខ្ទង់ឆ្នាំណា?

វ៉ែន ៖ ខ្ញុំមិនដឹងដែរ តែខ្ញុំថាផ្ដាច់ខ្លួន៩៣ទេ មិនដឹងប៉ុន្មាន។

ឈុនលី ៖ អ៊ំថាចង់ធ្វើកុម្មុយនីសវិញ ម៉េចខ្លះ?

វ៉ែន ៖ ហ្នឹងហើយប៉ុលពត គាត់មានគម្រោងចេញមក ប្រជាជននៅតាមមូលដ្ឋាននេះដករទេះគោដកមាសដកប្រាក់ ។

ឈុនលី ៖ ធ្វើដូចពីមុនជិនាន់៣ឆ្នាំ?

វ៉ែន ៖ ហ្នឹងហើយដកឡាន ដាក់ទៅកន្លែងរួម ខ្ញុំកាលនឹងមានឡានដែរ ខ្ញុំទិញអាដឹរដឹកឈើ ដល់ខ្ញុំដឹង ដែនការគាត់ដកអីចឹង បងសាម៉ែនអធិការសព្វថ្ងៃនេះ គាត់មេខ្ញុំតាំងពី៧៩មកនៅកន្លែងនេះ ។

ឈុនលី ៖ ឈ្មោះអីគេ?

វ៉ែន ៖ ម៉ី សាម៉ែន អធិការនេះមុនដំបូងធ្វើប្រធានឃុំបនៅតំបន់ម៉ាឡៃនឹង ដល់ផ្តាច់ខ្លួនហើយបាន គេលើកគាត់ឲ្យធ្វើអធិការស្រុក ។ ដល់ជំនាន់នោះ ខ្ញុំសុំច្បាប់គាត់ៗ ខ្ញុំថាបងឯងឲ្យច្បាប់ខ្ញុំមក ខ្ញុំយកឡានទៅលក់យាយអ៊ិតនៅព្រំដែនវត្តខាងតាជា ។ បានលក់រួចហើយម៉ាអាទិត្យ គេនេះចាប់ដកគោយន្តដកឡានអី ខ្ញុំរួចខ្លួនបាត់ ។

ឈុនលី ៖ ដល់ពេលអីចឹងម៉េចទៀត?

វ៉ែន ៖ ដល់នឹង លោកសុខ ភាព លោកប្រឆាំងនឹងរទេះគោៗនឹងរបស់ប្រជាជនគាត់ប្រកបមុខរបរអាជីវកម្ម ហើយដល់ប៉ុលពតវាដករទេះគោទៀតវាអស់ ។ ដល់អីចឹងវាទំនាស់កន្លែងនឹងសុន សេននេះ ថាគាត់ប្រឆាំង ថាគាត់ក្បត់ហើយ គេស្តទៅប្រាប់អ៊ី ឈាននៅប៉ៃលិនថារើ លេងគាត់នោះដែរ លេងអត់បែកមកលេងនេះ ដល់លេងនេះគេស្តទៅប្រាប់ទៀត២នាក់នេះរួមគ្នា ភ្នំព្រឹក សំពៅលូននៅកណ្តាលគាត់នៅកណ្តាលគ្មានរើអីរួច ។ ខាងអ៊ី ឈានមកពីនោះ ខាងសុខ ភាពទៅនេះខ្ទិបសំពៅលូននេះនៅកណ្តាល ។

ឈុនលី ៖ តាសុន សេននឹង ហើយនឹងតាមប៉ុល ពតនឹងគំនិតដូចគ្នា?

វ៉ែន ៖ ហ្នឹងហើយដូចគ្នា ចុះបញ្ជាពីប៉ុលពតមកសុន សេនៗខាងកងទ័ព ។

ឈុនលី ៖ ចុះតាប៉ុលពត?

វ៉ែន ៖ ប៉ុលពតក្តាប់រួមទាំងអស់ ។

ឈុនលី ៖ ចុះកាលនោះលោក សុខ ភាព គាត់ធ្វើអីគេ?

វ៉ែន ៖ គាត់កងពលៗនៅម៉ាឡៃ ។

ឈុនលី ៖ កងពលអីគេ លេខប៉ុន្មាន?

វ៉ែន ៖ កងពលប៉ុន្មានទេ៤៥០ ។

ឈុនលី ៖ ទីតាំងនៅណា?

វ៉ែន ៖ ទីតាំងនៅម៉ាឡៃនឹង គាត់ឈរជើងនៅចាប់ពីខ្វាងវាប់មកទល់នឹងស្រុកសំពៅលូននឹង ទល់ផ្លូវគីឡូ៩នេះ មុខសញ្ញាគាត់ហើយ ។

ឈុនលី ៖ ហើយដល់លោកអ៊ី ឈាននឹង?

វ៉ែន ៖ លោកអ៊ី ឈាននៅកាន់កាប់ខាងប៉ៃលិន ។

ឈុនលី ៖ ខាងកងទ័ព?

វ៉ែន ៖ ទ័ពដែរ ។

ឈុនលី ៖ ចឹងគាត់ស្មើនឹងលោកសុខ ភាព?

វ៉ែន ៖ ហ្នឹងដូចគ្នាកងពលដូចគ្នា គាត់ក្តាប់ទ័ពដល់សុន សេននេះគាត់ធ្វើខ្លាំងពេកទៅបានរើបណ្តោយរើរួច ។

ឈុនលី ៖ ដល់ពេលក្រោយមក តាប៉ុល ពត តាសុន សេន អត់ត្រូវគ្នា?

វ៉ែន ៖ ហ្នឹងហើយអានឹងវាអស់ហើយ អស់កម្លាំងហើយ ។

ឈុនលី ៖ ម៉េចក៏អត់ត្រូវគ្នាព្រោះបញ្ហាមកដូចគ្នា?

វ៉ែន ៖ បញ្ហាមកដូចគ្នា ប៉ុនដល់ធ្វើមិនមែនប៉ុលពតក្តាប់ផ្ទាល់ណា ប៉ុលពតគាត់ក្តាប់ប្រយោល ដល់សុន សេនគាត់ក្តាប់ផ្ទាល់ ។ ដូចសុន សេន គម្រោងដករទេះគោអី ប៉ុល ពតអត់ដឹងទេ ។

ឈុនលី ៖ ចុះម៉េចបានអ៊ំបានដឹងរឿងនឹងច្បាស់?

វ៉ែន ៖ ចុះបើខ្ញុំចុះជាប់ដែរ ខ្ញុំតាមដានដែរ ខ្ញុំជម្រាបប្អូនឯងដោយស្មោះ ខ្ញុំប៉ុលពតចាប់ដាក់គុកតាំងពីខែ១១ ៧៦ ។

ឈុនលី ៖ ម៉េចអ៊ីចឹង?

វ៉ែន ៖ ខ្ញុំជាប់គុកនៅខេត្តរតនគិរីនឹង ។

ឈុនលី ៖ ហេតុអីបានអ៊ីចឹង?

វ៉ែន ៖ ចុះខ្ញុំនិយាយមិញ ថាខ្ញុំអត់រណបទេរឿងមេៗណាធ្វើមិនស្រួលខ្ញុំប្រឆាំងរហូត ខ្ញុំសុខចិត្តជាប់គុក ។

ឈុនលី ៖ កាលនឹងរឿងអី?

វ៉ែន ៖ រឿងខ្ញុំគេហាមិនឲ្យហូបរហេតរហូត ហើយខ្ញុំអ្នកធ្វើការខ្លាំង ហើយខ្ញុំមេមួយដែរ ។

ឈុនលី ៖ មេអីគេ?

វ៉ែន ៖ មេកងតូចក្តាប់កងទ័ពនឹង ដល់ខ្ញុំលើកភ្លឺស្រែវាអស់កម្លាំង បាយស៊ីអត់ឆ្អែត ដល់ខ្ញុំទៅជីកអាដំឡូងជ្រៅបានប៉ុនៗនេះ យកមកស្ងោរហូប យកមកបបរចែកពួកមិត្តៗក្នុងក្រុមហូប ដល់ហើយគេថាខ្ញុំនេះ អត់ក្តាប់មាគ៌ារបស់បក្សគេថាគេកំចាត់កម្មសិទ្ធិសួនតួ តែយើងពង្រីកអាកម្មសិទ្ធិសួនតួ ឹងខ្ញុំកន្លែងនឹង ។ តែអាកងធំអីនៅក្តាប់ក្រុមខ្ញុំ កងខ្ញុំអត់ឲ្យស៊ីទេ តែខ្ញុំខឹងហើយខ្ញុំអត់ហៅស៊ីទេ ថ្នាក់ប៉ុន្មានក៏អត់ហៅស៊ីដែរ ។ ដល់ខឹងរាយការណ៍ទៅវរសេនាធំ ថាខ្ញុំខ្សែខ្មាំង ។ អានឹងសំណុំរឿងមានអីចាប់ខ្ញុំយកទៅដាក់គុកនៅកន្លែងកងពល ។ ដល់ទៅគេដាក់កន្លះខែ ចងដេកក៏ជាប់ ។

ឈុនលី ៈ គុកគេរបៀបម៉េច?

វ៉េន ៈ គុកផ្ទះយើងធម្មតាជំនាន់នឹង គ្មានគុកអីទេ គ្រាន់ចងដៃចងជើង គេខ្លាចយើងរត់ ដល់កន្លះខែបានគេហៅទៅសួរខ្មែរណាៗធ្វើអីខ្លាំងធ្វើអីៗ បានប៉ះខ្ញុំៗក៏មិនស្រែកអីខ្ញុំក៏មិនសួរ ព្រោះខ្ញុំអត់ដឹងរឿងខ្លួនឯងកំហុសខ្លួនឯង មិនដឹងខ្មែរខ្លាំងណា។ ខ្ញុំសួរវរសេនាធំ សួរគាត់ចាំមើលគាត់បើកសេចក្ដីរាយការណ៍ពីកងវរៈទៅសិន។ គាត់បើកមើលគាត់គ្រាន់តែឃើញថាខ្មែរយៈរបស់ខ្លាំងមិនដឹងអ្នកណាគេអ្នកបំពាក់ក៏អត់ដឹង។ ដល់អីចឹងវាលំបាកដោះស្រាយជាមួយខ្ញុំអីចឹង ខ្ញុំសួរបុសគល់ម៉េចទេ គាត់ថាធ្វើម៉េចបើបានមកដល់ហើយកសាងខ្លួនសារថ្មី។

ឈុនលី ៈ នៅដល់ពេលណា?

វ៉េន ៈ នៅទល់យួនចូល ប៉ុន្មានឆ្នាំ។

ឈុនលី ៈ តាំងពី៧៦?

វ៉េន ៈ ខែ១១ ៧៦ ។

ឈុនលី ៈ កាលនឹងអ៊ំកាន់ខាងកងវរសេនាតូច កាលនឹងមានកូនចៅប៉ុន្មាននាក់?

វ៉េន ៈ កងតូច មិនមែនវរសេនាតូចទេ កងតូច ៣០នាក់។

ឈុនលី ៈ ចុះកងវរសេនាតូចម៉េចវិញ?

វ៉េន ៈ វរសេនាតូចនឹងជាង១០០នាក់ ជិត២០០នឹងវរសេនាតូចអានឹងវា៣កងធំ ដល់កងធំនោះវាជាងខ្លះ១០០ ខ្លះជាង១០០ វា៣រយជាងវរសេនាតូច។ ដល់កងធំវាមាន១០០ ដល់កងតូចវាមាន៣០ ។

ឈុនលី ៈ ចុះដល់ពេលអ្នកគ្រប់គ្រងអាធំលើនឹង ឲ្យអស់ម៉ាកងពលធំនឹង?

វ៉េន ៈ អាកងពលនឹងមានរាប់ពាន់នាក់។

ឈុនលី ៈ អ៊ំថាឈ្មោះអីគេ?

វ៉េន ៈ សូ សារឿននឹងកងពលនឹង៣វរសេនាធំៗ ម៉ាវរសេនាធំមាន៣វរសេនាតូច។

ឈុនលី ៈ ហើយម៉ាវរសេនាតូចមាន?

វ៉េន ៈ មាន៣កងតូច ហ៎!ម៉ាវរសេនាតូចនឹងមាន៣កងធំទៀត។

ឈុនលី ៈ អ៊ំជាប់គុកនៅនឹង អត់មានអ្នកណាជួយអីទៀតទេ?

វ៉េន ៈ អត់មានទេ ជំនាន់នឹងអត់មានអ្នកណាជួយបានទេ ជួយខ្លួនឯង បើយើងខ្លាំងមែនទែនគឺចប់ហើយ ប៉ុន្តែខ្ញុំវាគ្រាន់ថាវាល្អៀង បើថាគេរិតខ្ញុំខ្លាំងខ្ញុំបន្ទន់ខ្លួនទំលាក់ខ្លួនធ្វើម៉េចឲ្យបានរស់សិនដល់ដំណាក់កាលយើងយក។

ឈុនលី ៈ ហើយដល់ពេល៧៩ អានឹងម៉េច?

វ៉ន ៖ ៧៩ យួនចូល ។

ឈុនលី ៖ មុននឹងបែកមានរឿងអីកើតឡើង?

វ៉ន ៖ ...វៀតណាមចូលវ៉ៃនៅរតនគិរី នៅកន្ទែងទ័ព ។

ឈុនលី ៖ មុនគេ?

វ៉ន ៖ វ៉ៃជុំវិញព្រំដែនវ៉ៃទាំងអស់ ប៉ុនគ្រាន់ថាចូលលឿនជាងគេ ។

ឈុនលី ៖ វាជិត?

វ៉ន ៖ បាទ! វាជិតទល់ដែនមុនគេ ។

ឈុនលី ៖ អានឹងខ្ទង់ខែណាឆ្នាំ៧៩?

វ៉ន ៖ ខ្ញុំរត់ពីខែ១១៧៨ យួនវ៉ៃ ។

ឈុនលី ៖ ដោយសារយើងនៅជិត?

វ៉ន ៖ បាទ! ខ្ញុំរត់បានម៉ាខែ ខ្ញុំរត់ចេញពីរតនគិរីនឹងទៅដល់ស្រុកជាំក្សាន្តខាងខេត្តថាឡាបរិវាត ។ ខ្ញុំរត់ទៅដល់សាលាស្រុកថាឡាបរិវាតនឹងបានយួនចូលដល់ភ្នំពេញ ស្តាប់វិទ្យុ ។

ឈុនលី ៖ នៅខេត្តណា?

វ៉ន ៖ នៅឧត្តរមានជ័យ ខេត្តថាឡាបរិវាត កាលនឹងខ្ញុំរត់ពីរតនគិរីមក ខ្ញុំរត់ពេញម៉ាសាខែ ដល់ស្តាប់វិទ្យុមើល យើងរត់តាមឡានមានឡានមានអីជិកចន្ទោះៗ ។ ដល់ទៅដល់សាលាស្រុកដែលបនឹង ម៉ោង៥សម្រាកបើប៉ុស្តិ៍វិទ្យុលែងឮបានដឹងថាយួនចូលដល់ភ្នំពេញ ខ្ញុំរត់ម៉ាខែមុន ។

ឈុនលី ៖ អានឹងពេលយើងរត់ទាំងកង?

វ៉ន ៖ រត់ទាំងកងទាំងអស់ ទាំងកងពល ។

ឈុនលី ៖ និយាយទៅខាងទ័ពនៅតំបន់ឥសាន្តមកទាំងអស់?

វ៉ន ៖ បាទ!មក ហ៎! ទ័ពគេនៅវ៉ៃម៉ាចំនួនមកនឹងតែខាងក្រសួងមន្ទីរហើយនឹងអ្នកដេកពេទ្យ ។

ឈុនលី ៖ ចុះដូចអ៎ី?

វ៉ន ៖ ខ្ញុំនៅខាងជាប់គុករត់នឹង រត់មកចូលក្រសួងមន្ទីរជាមួយគេនឹង ។

ឈុនលី ៖ គេហៅក្រសួង?

វ៉ន ៖ ក្រសួងមន្ទីរនៅក្នុងកងពលនឹង ។

ឈុនលី ៖ មន្ទីរអីគេ?

វ៉ន ៖ គេហៅមន្ទីរកងពលៗ ។

ឈុនលី ៖ ចុះអ្នកដែលនៅនឹងអ្នកម៉េច ដែលនៅច្បាំងជាមួយវៀតណាម?

វ៉ែន ៖ អានឹងកងទ័ពនៅនឹងទៅ យើងរត់មក យើងបែកគ្នារហូតមក ។ ខ្ញុំរត់មកបែកគេ ខ្ញុំមកបែក បានខ្ញុំមកចូលជាមួយបងសាម៉ែនអធិការនេះ ព្រោះខ្ញុំចេញពីនោះមកហើយ គេយកបញ្ជូនទៅវិញដែរ ប៉ុន្តែខ្ញុំអត់ទៅ បញ្ជូនទៅកងចាស់ ។

ឈុនលី ៖ ហើយចុះរត់ៗទៅទ័ពរត់ដល់ណា បន្ទាប់ៗធ្វើម៉េចដល់ទីកដី?

វ៉ែន ៖ អឺ! ខ្ញុំទៅឆ្ពាយបរតាំងស៊ូ ឆ្ពាយប៉ៃលិន ទៅវៃម៉ាជួរនឹងវៃរហូត ។

ឈុនលី ៖ ដល់ពេលអីចឹងអ៊ីគេដោះលែងពីគុកហើយ?

វ៉ែន ៖ គ្មានអ្នកណាគេដោះលែង យើងរត់យករួចខ្លួន យួនចូលស្រុកហើយ ។

ឈុនលី ៖ អត់មានជាប់ច្រវាក់ ជាប់អីទេ?

វ៉ែន ៖ អត់ទេ គេប្រលែងគេគ្រាន់ថាឃុំយើងទុកឲ្យធ្វើការធ្វើស្មៅដំឡូងស្មៅអំពៅ មានកងការពារគេដើរយាមយើង ។ ឧបមាម៉ាកងវរៈគាត់ជាប់គុកនឹងមានអ្នកការពារ៩នាក់ ២នាក់ស្ពាយកាំភ្លើងតាមយើង ម៉េចហៅអ្នកជាប់គុកឲ្យធ្វើការ អត់ធ្វើគេពិន័យទៀត ឈប់ក៏ប្រាប់គេ ឈឺនោមក៏ប្រាប់គេ អាចម៍ក៏ប្រាប់គេ ថាមិនប្រាប់គេដកបរបបាយទៀត ហើយយើងឈឺនោមយើងអត់ប្រាប់គេ អត់សុំគេដកបាយម៉ាផ្នែកចេញទៀត ។

ឈុនលី ៖ ដល់ពេលទៅដល់ប៉ៃលិននឹងម៉េចទៀត?

វ៉ែន ៖ វៃជាមួយខាងវៀតណាម ។

ឈុនលី ៖ វៀតណាមចូលដល់ណា?

វ៉ែន ៖ ពេញទាំងអស់នឹងគ្រប់ច្រកគ្រប់ទាំងអស់ដេញយើងគ្មាននៅបាន ។

ឈុនលី ៖ ពេលអ៊ំរត់ទៅដល់ប៉ៃលិននឹង វៀតណាមចូលដល់ណា?

វ៉ែន ៖ តាមក្រោយយើងបន្តៗ ការវាគៀកខ្លាំងយើងវៃ បើវៃបណ្តុះប្រជាជន ។

ឈុនលី ៖ ប្រជាជនច្រើនដែលមកជាមួយ?

វ៉ែន ៖ ច្រើនដែលនឹងរាប់ពាន់នាក់ ។

ឈុនលី ៖ មកពីខាងណា?

វ៉ែន ៖ គ្រប់តាមមូលដ្ឋាននឹង អីតាមក្នុងកងពលមួយមានប្រជាជនរាប់ពាន់នាក់ដែរ ហើយប្រជាជនតាមស្រុកតាមភូមិនឹងគាត់ខ្លាចយួនគាត់ចេះតែរត់ទៅ ។

ឈុនលី ៖ ប្រជាជនដែលនៅរតនគីរីនឹងគាត់រត់មកជាមួយដែរ?

វ៉ែន ៖ រត់មកៗតែម៉ាចំនួនៗគេអត់មកទេ ។

ឈុនលី ៖ បើអត់មកគាត់រត់ទៅណាវិញ?

វ៉ែន ៖ គាត់នៅនឹង ឧបមាថាអ្នកមូលដ្ឋានចាស់ គេអត់រត់ ។

ឈុនលី ៖ អ្នកស្រុកនៅនឹង?

វ៉េន ៖ គេម៉េចវត់ បើគេដឹងគេរត់មិនដឹងរត់ទៅណា បើជនជាតិគ្នារត់មិនដឹងរត់ទៅណា ដល់អីចឹង បេះទ្រាំនៅនឹងទៅ ហើយរតនគិរីសុទ្ធតែជនជាតិទេ ។

ឈុនលី ៖ កាលអ៊ំនៅជាមួយជនជាតិដែរ?

វ៉េន ៖ អត់ទេ យើងទ័ពយើងនៅផ្សេង ។

ឈុនលី ៖ តែនៅជិតភូមិជនជាតិ?

វ៉េន ៖ នៅជិតដែរ ប៉ុនគេអត់ឲ្យទាក់ទងទេ ជាមួយប្រជាជនទេសម័យនឹង ។

ឈុនលី ៖ ម៉េចអីចឹង?

វ៉េន ៖ មិនដឹងម៉េចបើផែនការរបស់ប៉ុលពតអត់ឲ្យទាក់ទងប្រជាជន ខ្ញុំនិយាយវែងឆ្ងាយរឿងជាប់គុក នឹងរឿងទាក់ទងប្រជាជន ដូចជាប្រឆាំងនឹងគេមិនឲ្យទាក់ទង យើងទាក់ទង ។

ឈុនលី ៖ ទាក់ទងរបៀបម៉េច?

វ៉េន ៖ ទាក់ទងរកដូចប្រជាជនអីចឹង ទ័ពយើងនៅជិតយើងទៅរាប់អានទៅលេងទៅសើចគាត់សួរនាំរកនេះ រកបន្លែរកបង្គារទៅស្ងហូប ។

ឈុនលី ៖ គេចោទថាម៉េច?

វ៉េន ៖ គេចោទថាយើងខុស ។

ឈុនលី ៖ ខុសសីលធម៌?

វ៉េន ៖ អត់ទេ និយាយថាយើងអត់គោរពវិន័យគេ គេហាមមិនឲ្យយើងទាក់ទងយើងទៅទាក់ទង បើគេហាមមិនឲ្យធ្វើអី យើងធ្វើនឹង ។

ឈុនលី ៖ ក្រោយមកពេលមកនៅប៉ៃលិន ក្រោមការគ្រប់គ្រងរបស់អ្នកណាគេ?

វ៉េន ៖ អត់ អានឹងផ្សេងទេ អានឹងគេបង្កើតកងផ្សេង ។

ឈុនលី ៖ បង្កើតពេលណា?

វ៉េន ៖ បង្កើតបើគេរត់ ព្រោះកងពលនឹងគាត់នៅឈរជើងវ៉ៃនៅនោះ ខ្ញុំរត់មកនេះគេយកអ្នកមន្ទីរនឹងឲ្យបង្កើតកងថ្មី រៀបម៉ាកងថ្មីការពារប្រជាជនរត់មកព្រំដែនថៃដើម្បីស្វែងរកអង្គការ គេថាអង្គការខ្មែរក្រហមនៅថៃ យើងរត់រកបង្អែក ។

ឈុនលី ៖ អង្គការខ្មែរក្រហម?

វ៉េន ៖ ហ្នឹងហើយគេហៅអង្គការ ។

ឈុនលី ៖ ខ្មែរក្រហមនឹង?

វ៉េន ៖ ហ្នឹងហើយ ខ្មែរក្រហមគេហៅអង្គការ។គឺប្រធានអ្នកដឹកនាំហើយគេហៅអង្គការ ។

ឈុនលី ៖ ពេលនឹងអ៊ំដឹងទេ ថាអង្គការនឹងអ្នកណាគេ?

វ៉ន ៖ ប៉ុលពតនឹង ថ្នាក់ដឹកនាំ ។

ឈុនលី ៖ ចុះពេលរត់នឹងតាប៉ុលពតនៅណា?

វ៉ន ៖ នៅតាមថៃ រត់ប្រទេសថៃចល័ត ។

ឈុនលី ៖ ចុះតាម៉ុក?

វ៉ន ៖ តាម៉ុកក៏នៅប្រទេសថៃ មេៗធំៗ ។

ឈុនលី ៖ ចុះតាខៀវ សំផន?

វ៉ន ៖ ហ្នឹងក៏នៅខាងប្រទេសថៃ ។

ឈុនលី ៖ ចុះដល់ពេលអ៊ំបានចូលដល់ដីប៉ៃលិនអានឹងខួងឆ្នាំណា?

វ៉ន ៖ ឆ្នាំរត់នឹងម៉ង ។

ឈុនលី ៖ ៧៩?

វ៉ន ៖ ហ្នឹង៧៩ ។

ឈុនលី ៖ ចុះឆ្នាំ៨០នៅណា?

វ៉ន ៖ ឆ្នាំ៨០ខ្ញុំមកឈរជើងនៅនេះហើយ មកនៅម៉ាឡៃនឹង ។

ឈុនលី ៖ កាលនឹងគេហៅស្រុកម៉ាឡៃនៅ?

វ៉ន ៖ នៅទេ គេហៅតំបន់១០២ ។

ឈុនលី ៖ ហើយអ្នកណាអ្នកគ្រប់គ្រងទូទៅនៅតំបន់១០២?

វ៉ន ៖ តំបន់១០២នឹង ថ្នាក់ដឹកនាំទី១តាដូត គាត់មុនគេៗឲ្យគាត់ធ្វើគណៈតំបន់ ។

ឈុនលី ៖ ជនជាតិអីគេ?

វ៉ន ៖ ជនជាតិចារាយនៅខេត្តរតនគិរី ហ្នឹងគាត់រត់មកពីនោះជាមួយគ្នា ។

ឈុនលី ៖ ឈ្មោះអីគេ?

វ៉ន ៖ ឈ្មោះ តាដូតស្លាប់បាត់ហើយ ។

ឈុនលី ៖ ត្រកូលអីគេ?

វ៉ន ៖ អត់ស្គាល់ឈ្មោះគាត់ ហើយតាដូតនឹង ខ្ញុំទើបស្គាល់គាត់នៅនេះទេ ដល់គាត់ដឹងថាខ្ញុំនៅរតនគិរីដែរ ហើយខ្ញុំនៅខាងពិសេស គេហៅកងពិសេសរបស់មជ្ឈិមបក្សៗកុម្មុយនីស គាត់ដឹងថាខ្ញុំនៅរតនគិរី ខ្ញុំនៅខាងលើគាត់នៅខាងក្រោម គាត់នៅតំបន់ ដល់គាត់ស្គាល់ខ្ញុំសួរដំណើរទំនងដឹងគាត់ឲ្យខ្ញុំនៅជាមួយគាត់បណ្ដោយ ។

ឈុនលី ៖ បើគិតទៅតាដូតនឹង គាត់នៅរតនគិរី គាត់ធ្វើអីគេ?

វ៉ែន ៖ គាត់នៅខាងតំបន់ ។

ឈុនលី ៖ មេតំបន់?

វ៉ែន ៖ នៅក្នុងមន្ទីរ ខ្ញុំភ្លេចអត់បានទេ គាត់នៅក្នុងមន្ទីរតំបន់ ។

ឈុនលី ៖ ប្រហែលមេ?

វ៉ែន ៖ មេដែលបានមក ។

ឈុនលី ៖ ហើយមកដល់នេះឲ្យធ្វើមេទៀត?

វ៉ែន ៖ ដល់មកនេះឲ្យធ្វើមេ ។

ឈុនលី ៖ ប្រធានតំបន់១០២?

វ៉ែន ៖ បាទ! គណៈតំបន់ ។

ឈុនលី ៖ អានឹងគាត់គ្រប់គ្រងទាហាន ហើយនឹងទាំងទ័ពទាំងប្រជាជន?

វ៉ែន ៖ អត់ទេ ទ័ពអត់មានទេ គណៈតំបន់នឹងគេចង់គ្រប់គ្រងខាងមូលដ្ឋាន ពិសេសខាងដឹកជញ្ជូន ។

ឈុនលី ៖ តំបន់នឹង?

វ៉ែន ៖ បាទ!

ឈុនលី ៖ ចុះលោកសុខ ភាព ពេលណា?

វ៉ែន ៖ លោកសុខ ភាពគាត់ទើបឡើងក្រោយទេ គាត់ខាងកងវរៈមុនដំបូង ។

ឈុនលី ៖ កងវរៈនៅណា?

វ៉ែន ៖ កងវរៈនៅនឹងម៉ង់ៗបងភាព គាត់អត់ទាន់ឡើងកងពល ។

ឈុនលី ៖ ចុះបើគិតអ្នកដែលគ្រប់គ្រងតំបន់១០២មុននឹងពេលតាជូតនឹងមាន?

វ៉ែន ៖ អត់ៗមានទេ មានត្រឹមគាត់នឹង រួចមកគេតែងតាំងនឹងឲ្យគ្រប់គ្រងក្នុងតំបន់នឹង តំបន់ចាប់ពីខ្វាងរាប់ទៅសំពៅលូនមានគាត់នឹងអ្នកគ្រប់គ្រងម៉ាប៉ែកនឹង ។

ឈុនលី ៖ អានឹងគេហៅនៅប៉ែកខាងណា?

វ៉ែន ៖ តំបន់១០២ ។

ឈុនលី ៖ ខាងភូមិភាគពាយ័ព្យនឹង?

វ៉ែន ៖ បាទ!

ឈុនលី ៖ ចុះតាអៀង សារី កាលនឹងគាត់នៅណា?

វ៉ែន ៖ គាត់ចល័ត គាត់នៅនឹងដែរ តែគាត់ចល័ត គាត់ចូលមកធ្វើការម៉ាភ្លែតៗគាត់ចេញទៅថៃ ។

ឈុនលី ៖ ដូចរបៀបគាត់គ្រប់គ្រងតំបន់?

វ៉ែន ៖ អត់ទេ គាត់ខាងមជ្ឈឹមជាមួយសុន សេន ជាមួយប៉ុលពតនឹង ។

ឈុនលី ៖ បើគិតទៅតួនាទីគាត់អីខ្វះទៅ ដូចថាគាត់ប៉ុន្មាននាក់នឹង?

វ៉ន ៖ គាអៀង សារីនឹង គាត់ក្រសួងការបរទេស ។

ឈុនលី ៖ កាលជំនាន់៣?

វ៉ន ៖ បាទ! អានឹងវាដំណជាប់មកអាណត្តិការងារគាត់ជាប់មកអីចឹង ។

ឈុនលី ៖ គាត់ធ្វើការងារដដែល គ្រាន់ថាយើងរត់?

វ៉ន ៖ បាទ! យើងរត់ក៏គេនៅតែក្រសួងការបរទេស ប៉ុនគ្រាន់ថាក្រសួងការបរទេសគេចែកមុខសញ្ញាគ្នាក្តាប់ ។ ឧបមាប៉ុលពតចុះខាងអន្លង់វែង អៀង សារី ។

ឈុនលី ៖ ពេលដែលយើងរត់មក គេចែកការងារគ្នាតាមមើលអីចឹង?

វ៉ន ៖ បាទ! គេចែក ។

ឈុនលី ៖ គាប៉ុលពតនៅខាងអន្លង់វែង?

វ៉ន ៖ អន្លង់វែង ហើយសុន សេននៅសំពៅលូន ហើយអៀង សារីនៅនេះ ។

ឈុនលី ៖ គាអៀង សារីមើលនៅក្នុងស្រុកម៉ាឡៃ?

វ៉ន ៖ បាទ! នៅម៉ាឡៃ ។

ឈុនលី ៖ តែគាត់ចេញចូលថៃ?

វ៉ន ៖ ចេញចូលថៃបន្ទាប់ពីតាជូតទៅបានឡើងខ្មោចតាយ៉ែមៗគាត់ធ្វើទូតកូរ៉េអានឹងសម័យ៣ឆ្នាំ ។

ឈុនលី ៖ ឈ្មោះអីគេយ៉ែម?

វ៉ន ៖ យិន យ៉ែម ។

ឈុនលី ៖ គាត់រស់នៅ?

វ៉ន ៖ អត់ទេស្លាប់បាត់ហើយ ទើបស្លាប់ឆ្នាំ៨៥ រត់ពីថៃពេលគេដោះមីនបានចូលមកជាមួយខ្ញុំចូលមក ។

ឈុនលី ៖ ម៉េចទៀតទៅ?

វ៉ន ៖ ខ្យល់ព្យុះវាវៃដើមស្រឡៅដួលមកប៉ះគាត់នៅក្នុងផ្ទះ គាត់ស្លាប់ទៅ ។ ដូច្នេះ ស្លាប់អស់២ហើយគណៈតំបន់ ។

ឈុនលី ៖ គណៈតំបន់?

វ៉ន ៖ បាទ! គណៈតំបន់ ។

ឈុនលី ៖ តាជូត ហើយនឹង?

វ៉ន ៖ តាយ៉ែម ។

ឈុនលី ៖ ក្រោយមកទៀតបាន?

វ៉េន ៖ បានលោកឈឹម មុនី ។

ឈុនលី ៖ គាត់ឡើងពេលណា?

វ៉េន ៖ ឡើងពេលយើងផ្តាច់ខ្លួន ឈឹម មុនីឡើងចៅហ្វាយស្រុក គាត់ផ្តាច់ខ្លួននេះបង្កើតជាស្រុក ។

ឈុនលី ៖ ពេលផ្តាច់ខ្លួនហើយ បង្កើតជាស្រុក?

វ៉េន ៖ បាទ! ផ្តាច់ខ្លួនហើតយ បង្កើតជាស្រុកបានឲ្យឈឹម មុនីធ្វើចៅហ្វាយស្រុកបណ្តោយ ។

ឈុនលី ៖ លោក ឈឹម មុនីនឹង ឥឡូវគាត់នៅណា?

វ៉េន ៖ គាត់ ពួសម្តេចនាយកគាត់ដកទៅនៅស្រុកព្រះនេត្រព្រះ ថាការងារអីទេ ឥឡូវឡើងទៅដក បាត់២អាណត្តិហើយ ។

ឈុនលី ៖ ចុះដល់ពេលអ៊ំចូមកដល់ទឹកដីម៉ាឡៃដីបូង នៅឆ្នាំណា បើយើងរត់មកយូរហើយ?

វ៉េន ៖ តាំងពីឆ្នាំ៧៩នឹងមក រត់យួនមកដល់នឹង ។

ឈុនលី ៖ ទីតាំងដីបូងនៅណា?

វ៉េន ៖ នៅភូមិដូង នៅនឹងគល់ស្ពាន ។

ឈុនលី ៖ ស្ពានព្រំដែន?

វ៉េន ៖ បាទ! ស្ពានព្រំដែន ។

ឈុនលី ៖ ម៉េចបានភូមិដូងនឹងធំម៉េច គេហៅកន្លែងណាក៏ភូមិដូង?

វ៉េន ៖ ភូមិដូងនឹង អាចំនុចចំការដូងនៅដីថៃ ដល់យើងនាំគ្នាទៅនៅភូមិដូងដីថៃ វាជាជាប់នឹងភូមិដូង កាកបាទយកអន្តរមកចែកនៅនឹង ។

ឈុនលី ៖ មានភូមិដូង មានឃុំអី?

វ៉េន ៖ នៅឃុំម៉ាឡៃនឹង ។

ឈុនលី ៖ ប៉ុន្តែពីមុនមកគេមានឃុំ?

វ៉េន ៖ អត់មានឃុំទេ ។

ឈុនលី ៖ គេហៅតែភូមិដូង?

វ៉េន ៖ ភូមិដូងៗដីថៃទេ ។

ឈុនលី ៖ ដីថៃ ដីខ្មែរ?

វ៉េន ៖ ដីថៃ ។

ឈុនលី ៖ អានឹងក្រែដីយើង?

វ៉េន ៖ អត់ទេ ដីដែចំការដូងនៅខាងនោះអូរ អាភូមិដូងនៅលើដីខ្មែរនេះ យើងយកឈ្មោះគេមកដាក់ ។

ឈុនលី ៖ តាមពិតគេមានឈ្មោះអីចឹងដែរ?

វ៉េន ៖ អត់ទេ អាភូមិដូងភូមិដីថៃនឹង ភូមិគេផ្សេង ប៉ុនយើងដាក់គ្នាយើងព្រោះកន្លែងនឹងវាកន្លែងចែកអន្តរៗ ។

ឈុនលី ៖ នៅលើដីខ្មែរយើងទេ?

វ៉េន ៖ នៅដីថៃ ។

ឈុនលី ៖ ហើយយកឈ្មោះរបស់គេមកដាក់?

វ៉េន ៖ មុនដំបូងនៅដីថៃទេ ភូមិដូងថៃ ចំការដូងថៃនឹង យើងយកចំការដូងនឹងហៅភូមិដូង ហើយដល់យើងផ្តាច់ ។

ឈុនលី ៖ ប៉ុន្តែនៅស្ថានខាងនេះរបស់ខ្មែរ?

វ៉េន ៖ ហើយឥឡូវដីយើងហើយ ព្រោះយើងហៅខាងនេះស្ថានខាងនេះអូរ យើងយកអាភូមិដូងចាស់ទៅដាក់នៅដីយើងបណ្តោយ ពីមុននៅដីថៃ ។

ឈុនលី ៖ គេអត់រករឿងយើងទេ?

វ៉េន ៖ គ្មានរកអីយើង គ្រាន់តែអ្នកហៅៗ ភូមិគេមិនមែនភូមិដូងណា ភូមិថៃ...គេផ្សេង មិនមែនឈ្មោះភូមិដូងទេ យើងនេះហៅគ្នាយើង ។

ឈុនលី ៖ ដល់ពេលស្រុកម៉ាឡៃនេះ ហេតុអីបានយើងដាក់ឈ្មោះម៉ាឡៃ?

វ៉េន ៖ យើងដាក់យកភ្នំម៉ាឡៃយកទៅស្រុក ។

ឈុនលី ៖ ពីដំបូងមកឈ្មោះម៉ាឡៃអីចឹងភ្នំនឹង?

វ៉េន ៖ ហ៎! ខ្ញុំអត់ដឹងដែរ ដល់មកដល់គេហៅភ្នំម៉ាឡៃៗគេហៅតៗគ្នាមក ។

ឈុនលី ៖ គេហៅតំបន់ភ្នំម៉ាឡៃ?

វ៉េន ៖ បាទ! ដល់យើងមានទ័ពហៅកងពលហៅអីហើយ សំខាន់ទើបផ្តាច់ខ្លួននេះទេ បានយើងដាក់ស្រុកម៉ាឡៃ យើងយកភ្នំ ពីព្រោះភ្នំនឹងមានសារតាំងពីដើមមក ។

ឈុនលី ៖ ដល់ពេលនឹងគេដូរចៅហ្វាយស្រុក?

វ៉េន ៖ បាទ!

ឈុនលី ៖ អ្នកណាគេអ្នកឡើង?

វ៉េន ៖ ឡើងទេព ខុនណាល់សព្វថ្ងៃ ។

ឈុនលី ៖ ឡើងពេលផ្តាច់ខ្លួនហើយ?

វ៉េន ៖ ហ៎! អត់ទេ ទេព ខុនណាល់គាត់ទើបបោះឆ្នោត ។

ឈុនលី ៖ ចុះដល់ពេលផ្តាច់ខ្លួនហើយអ្នកណាគេ?

វ៉េន ៖ ឈឹម មុនី ។

ឈុនលី ៖ មុនពេលផ្តាច់ខ្លួនឈ្មោះ?

វ៉េន ៖ តាជូត ។

ឈុនលី ៖ តាជូត ហើយតាយ៉ៃ?

វ៉េន ៖ បាទ! តាយ៉ៃក្រោយ ។

ឈុនលី ៖ គិតទៅតាជូតនឹងដល់ឆ្នាំណា បានឈប់?

វ៉េន ៖ តាជូត គាត់អត់ឈប់គាត់ដើរដុះមីន ។

ឈុនលី ៖ ឆ្នាំណា?

វ៉េន ៖ អត់សូវចាំ ប៉ុនគាត់បានតែម៉ាឆ្នាំជាងអត់ដល់២ឆ្នាំ ព្រោះកាលគាត់ឡើងតំបន់នឹងក្នុងឆ្នាំ៨០ ហើយខ្ញុំសុំគាត់ការប្រពន្ធក៏ឆ្នាំ៨០ដែរ ។ គាត់ការហើយបានប៉ុន្មានខែ គាត់ជាន់មីនស្លាប់ទៅ ។

ឈុនលី ៖ ហេតុអីបានអីចឹង?

វ៉េន ៖ ចុះគាត់ដើរធ្វើការជាមួយនារសាកងការពារនឹងដើរធ្វើការតាមផ្លូវ ។ ដល់ហើយមេឃភ្លៀង វាព្រិលភ្នែក ។

ឈុនលី ៖ បើគិតទៅតាជូតនឹងស្និតស្នាលជាមួយតាអៀង សារីអត់?

វ៉េន ៖ គាត់ស្និលស្នាលហើយ ព្រោះគាត់ចាត់តាំងហើយ អ៊ំអៀង សារីឲ្យតាជូតនឹងធ្វើគណៈតំបន់ហើយ ។

ឈុនលី ៖ គាត់ក្រោមតាអៀង សារីតិច?

វ៉េន ៖ អត់ទេ គាត់ខាងខ្មែរគណរដ្ឋមន្ត្រី អត់មានពាក់ព័ន្ធទេ គ្រាន់ថាគណៈតំបន់បណ្តោះអាសន្នដែលយើងឲ្យមានអ្នកគ្រប់គ្រងពេលក្នុងយើងតស៊ូម៉ារយៈខ្លី ។

ឈុនលី ៖ តែពេលនឹងតាអៀង សារីអ្នកតែងតាំង?

វ៉េន ៖ បាទ! ពេលនឹងតាវី អ្នកតែងតាំង ។

ឈុនលី ៖ ចុះអ្នកណានៅអែបគាត់?

វ៉េន ៖ អែមណាគេ?

ឈុនលី ៖ អែមតាអៀង សារី?

វ៉េន ៖ អានឹងគេផ្សេងទៀត ។

ឈុនលី ៖ ចុះដល់ពេលមកដល់ស្រុកនេះអ៊ំនៅធ្វើអីគេ ធ្វើទ័ព?

វ៉េន ៖ ខ្ញុំធ្វើទ័ពរហូត ។

ឈុនលី ៖ គេអត់ឲ្យកាន់ខាងមេក្រុមមេអី?

វ៉ែន ៖ អត់ទេ ខ្ញុំនៅយុទ្ធជនរហូត ដល់ខ្ញុំអត់គោរពទេមេ ព្រោះខ្ញុំអត់ចេះរណេរណម ប៉ុនរឿងប្រយុទ្ធខ្ញុំអត់ចេះខ្លាច បើថាឲ្យធ្វើៗតែខ្ញុំថាធ្វើៗ បើខ្ញុំមិនធ្វើមិនបាច់ត្រូណាមកប្រើខ្ញុំទេ មេប៉ុនណាក៏ខ្ញុំមិនចេះខ្លាចដែរ តែខ្ញុំមិនធ្វើតែអីចឹង ។

ឈុនលី ៖ ម៉េចបានអីចឹង?

វ៉ែន ៖ អត្តចរិតរបស់ខ្ញុំតែអីចឹង ធ្វើអីទាល់តែខ្ញុំច្បាស់របស់ខ្ញុំបានខ្ញុំធ្វើ បើថាចាត់តាំងមានរបៀបប្រលេប្រឡូអត់ស្មោះ ហើយមេឯងមិនចាំបាច់បន្ទុំទេ មិនបាច់ចង់ឈ្នះទេ ។

ឈុនលី ៖ ពេលអ៊ំមកដល់នេះមានរឿងជាមួយមេ?

វ៉ែន ៖ នៅតែមានគ្រប់មេ បងសាម៉ននេះក៏ខ្ញុំធ្លាប់ឈ្លោះជាមួយគាត់ដែរ ។

ឈុនលី ៖ អ៊ំថាសាម៉ន គាត់ត្រកូលអីគេ?

វ៉ែន ៖ ម៉ុៗ សាម៉ន ។

ឈុនលី ៖ ម៉ុ សាម៉ននឹង ពីដំបូងមកគាត់កាន់ខាងទ័ព?

វ៉ែន ៖ អត់ទេ គាត់សម័យ៣ឆ្នាំ គាត់ខាងសំអាតនៅទីក្រុងភ្នំពេញ ។

ឈុនលី ៖ ខាងបោសសំអាត?

វ៉ែន ៖ ហ្នឹងហើយ ខាងដឹកសំរាម ដឹកអី ដូច្នេះគេហៅក្រសួងមន្ទីរហើយ ។

ឈុនលី ៖ ចុះមកដល់នេះភ្លាម?

វ៉ែន ៖ មកដល់នេះភ្លាម បានជាមួយអ៊ំអៀង សារីៗចាត់តាំងឲ្យគាត់ធ្វើប្រធានឈ្លបៗការពារតំបន់ខាងក្រោយ ការពារប្រជាជន ការពារដឹកជញ្ជូន ។

ឈុនលី ៖ នៅតំបន់១០២?

វ៉ែន ៖ បាទ! នៅ១០២ ឈ្លបនឹងគេហៅការពារសន្តិសុខ ខាងសណ្តាប់ធ្នាប់សន្តិសុខ ។

ឈុនលី ៖ ហើយគ្រប់គ្រងទាំងអ៊ំទៀត?

វ៉ែន ៖ ចុះគាត់ប្រធាន ហើយខ្ញុំ ។

ឈុនលី ៖ គ្រែងអ៊ំខាងទ័ព?

វ៉ែន ៖ ទ័ព ប៉ុនដូចខ្ញុំនិយាយស្តាប់អត់ទាន់ ដល់ខ្ញុំរបួសដេកពេទ្យនេះ កងគេទៅខាងអន្លង់វែងទៅ គេបញ្ជូនខ្ញុំទៅ ខ្ញុំអត់ទៅគេឲ្យខ្ញុំមកនៅជាមួយបងសាម៉ន ជាមួយតាជូតនឹងចូលក្នុងកងថ្មីៗរបស់ខ្ញុំហើយ ។

ឈុនលី ៖ ឆ្នាំណា?

វ៉ែន ៖ ឆ្នាំ៨០ នៅក្នុង៧៩នឹង ។

ឈុនលី ៖ បើគិតទៅអឺមកដល់ទឹកដីនេះ ម៉ាឡៃឆ្នាំ៧៩?

វ៉េន ៖ បាទ! ៧៩នឹង ។

ឈុនលី ៖ មកនៅដំបូងស្ថានភាពម៉េចទៅ?

វ៉េន ៖ មានព្រៃឫស្សី មានមីនមានអីពេញទាំងអស់នឹង ព្រៃណែនគាន់គាប់ដូចមិនមែនមានវាលមាន អីចេះណា ព្រៃទាំងអស់ ។

ឈុនលី ៖ ហើយយើងនៅម៉េច?

វ៉េន ៖ យើងឆ្ការនៅពីក្រោមព្រៃ ធ្វើដំបូលកៅស៊ូធ្វើគ្រែដេក ។

ឈុនលី ៖ ចុះរបៀបជាកងជាអី យើងធ្វើជាសហករណ៍?

វ៉េន ៖ អត់ទេ អត់មានសហករណ៍អីទៀតទេ អានឹងហូបបាយតាមក្រុម ។

ឈុនលី ៖ គេចែកឲ្យ?

វ៉េន ៖ បាទ! កាកបាទគេចែកអង្ករឲ្យ ។

ឈុនលី ៖ កាកបាទក្រហម?

វ៉េន ៖ កាកបាទក្រហម ។

ឈុនលី ៖ មកចែកនៅភូមិដូង?

វ៉េន ៖ ហ្នឹងហើយ ដឹកឡានមកចែកនៅភូមិដូង ហើយយើងដល់ថ្ងៃយើងទៅបើកណា ។

ឈុនលី ៖ គាដូតនឹងអ្នកដឹកនាំមក?

វ៉េន ៖ អត់ទេ គាដូតនឹងគាត់នៅម៉ាកន្លែងមានមេក្រុមមេកងទទួលពីកាកបាទមក ។

ឈុនលី ៖ អ្នកនាំទៅទទួលអំណោយនឹងអ្នកណាគេ?

វ៉េន ៖ ខាងប្រធានដឹកជញ្ជូន កងនារីដឹកជញ្ជូន ។

ឈុនលី ៖ ស្គាល់?

វ៉េន ៖ គាត់នៅយាយហៀង កងប្រធាននារីនៅសព្វថ្ងៃ ។

ឈុនលី ៖ យាយហៀង?

វ៉េន ៖ យាយហៀង ប្រធាននារីស្រុក ។

ឈុនលី ៖ ប្រធាននារីដឹកជញ្ជូនស្រុក?

វ៉េន ៖ អត់ទេ ឥឡូវនេះ គាត់ប្រធាននារី ។

ឈុនលី ៖ ចុះពីដើមកាលពេលមកនៅភ្នំមនឹង តួនាទីគាត់អីគេ?

រ៉េន ៖ ពីដើម វាគាត់ពីដើមតស៊ូដែរនឹង គាត់ប្រធាននារីដែរ ដល់ផ្តាច់ខ្លួននេះហើយ គេចាត់តាំងឲ្យគាត់នឹងធ្វើប្រធាននារី ។ ចុះគេបង្កើត អានឹងគេមាននារីមានអី គេបង្កើតឲ្យគាត់ឡើងធ្វើប្រធាននារី ។

ឈុនលី ៖ គាត់នៅណាយាយហៀង?

រ៉េន ៖ ស្រុកកំណើត?

ឈុនលី ៖ អត់ទេ ឥឡូវ?

រ៉េន ៖ ឥឡូវនៅភូមិដូង ។ នៅវាលហាត់ ម្តុំវាលហាត់ អាខាងនេះស្ពាន ។

ឈុនលី ៖ ឥឡូវគាត់ធ្វើការអី?

រ៉េន ៖ ឥឡូវគាត់ប្រធាននារី ។

ឈុនលី ៖ ឥឡូវនឹងប្រធាននារីស្រុក?

រ៉េន ៖ ប្រធាននារីស្រុកម៉ាឡៃនឹង ។

ឈុនលី ៖ គាត់កាចទេ?

រ៉េន ៖ គាត់អត់កាច គាត់មិនសូវចេះមាត់ ។

ឈុនលី ៖ អាយុប៉ុន្មាន?

រ៉េន ៖ អាយុស្រករខ្ញុំដែរ ៥០ជាង ។

ឈុនលី ៖ អ៊ំថា៥០ប៉ុន្មាន?

រ៉េន ៖ ខ្ញុំ៥៨ ។

ឈុនលី ៖ ដល់ពេលមកដល់នឹង អ៊ំថាមកដំបូងមានព្រៃមានអី ហើយចាញ់ច្រើនទេ?

រ៉េន ៖ ចាញ់ រឿងចាញ់លែងនិយាយ ហើយខ្ញុំវាបានដើរច្រើន ដើររាប់កន្លែងអស់ហើយ រឿងចាញ់ដូច...លែងសូវគិតលែងសូវគួរ ។

ឈុនលី ៖ អ៊ំបានជម្លៀសទៅខាងថៃនឹងគេ?

រ៉េន ៖ ទៅ ចុះយួនមកវ៉ៃខ្លាំងរត់ចូលថៃទៅ ។

ឈុនលី ៖ ចុះតំបន់នឹងមានមីនទេ?

រ៉េន ៖ មីន ។

ឈុនលី ៖ មីនពេលណា?

រ៉េន ៖ មីនគេដាក់ការពារតាំងពីសម័យ៣ឆ្នាំនឹងមក ដល់យើងមកដល់យើងមកនៅយើងដោះ ។

ឈុនលី ៖ ចុះសម័យ៣ឆ្នាំនឹង នៅតំបន់នឹងមានប្រជាជនរស់នៅដែរ?

រ៉េន ៖ មានពួកខាងតស៊ូ ពួកខាងប៉ុល ។

ឃុនលី : ប៉ាវ៉ាទីងខាងណា?

វ៉ែន : ប៉ាវ៉ាទីងខាងខ្មែរលន់ នល់ ដល់ខ្មែរក្រហមវ៉ៃ ខ្មែរលន់ នល់បាក់អាខ្លះទៅបរទេស ទាហានៗ ចូលថៃដូចគ្នា តស៊ូប្រឆាំងនឹងខ្មែរក្រហមនឹងគេហៅប៉ាវ៉ាទីង តាសឹន សាននីង មុនដំបូងមិន ខាងប៉ាវ៉ាទីង ញឹក ប៊ុនឆៃនឹងៗ គាត់នៅខាងខ្មែរលន់ នល់ដែរ ទំនាស់ជាមួយខ្មែរក្រហម អីចឹងបានថាវ៉ៃតែគ្នាឯង ។

ឃុនលី : កាលនឹងគាត់នៅណា ញឹក ប៊ុនឆៃ?

វ៉ែន : ប៊ុនឆៃនៅខាងលន់ នល់ ។

ឃុនលី : ប៉ុន្តែគាត់គ្រប់គ្រងនៅ?

វ៉ែន : នៅខាងប៉ោយប៉ែតនឹង មុខសញ្ញាគាត់អូរជ្រៅប៉ោយប៉ែតនឹង ។

ឃុនលី : ចុះអ៊ំថានៅតំបន់នឹងមានគេនៅ តើមានប្រជាជនមានអីដែរ?

វ៉ែន : ប្រជាជនមាន បើខាងប្រពន្ធកងទ័ពអីនៅជាប់ ។

ឃុនលី : ខ្ទង់ជំនាន់ពាឆ្នាំ?

វ៉ែន : បាទ!

ឃុនលី : អ្នកស្រុកនេះគេរស់នៅយ៉ាងម៉េច?

វ៉ែន : គេរស់នៅតាមព្រំដែន ធ្វើផ្ទះតូចៗនៅតាមមាត់អូរ ។

ឃុនលី : មានព្រៃ?

វ៉ែន : ព្រៃស្តុកដូចគ្នា ចេះនៅក្រោម ។

ឃុនលី : ចុះមិនចាញ់?

វ៉ែន : ចាញ់ចេះចាញ់ធ្វើម៉េច អ្នកស្លាប់ៗ អ្នកនៅរស់ចេះនៅ ។

ឃុនលី : ចុះធ្វើទ័ពយើងទៅច្បាំងជាមួយគេនៅសមរភូមិ?

វ៉ែន : បាទ!

ឃុនលី : សមរភូមិនៅណា?

វ៉ែន : សមរភូមិចូលទៅក្នុង ។

ឃុនលី : តំបន់អីគេ?

វ៉ែន : មិនដឹងតំបន់នៅខេត្តបន្ទាយមានជ័យ ។

ឃុនលី : ចុះកន្លែងខ្លាងាប់?

វ៉ែន : ហ្នឹងហើយទៅសមរភូមិ ទៅវ៉ៃតាមនឹង ។

ឃុនលី : អ៊ំស្គាល់ ម៉ក់ ហឺននឹងដែរ?

វ៉ែន ៖ ជីស្គាល់ ទៅវ៉ៃតាគង់តាអី ទៅវ៉ៃតាមនឹងហើយ ។

ឈុនលី ៖ ឃុំ?

វ៉ែន ៖ ហ្នឹងហើយ ឥឡូវគេដាក់ឃុំ ។

ឈុនលី ៖ កន្លែងម៉ក់ហឹន ក្រៅពីសមរភូមិ អានឹងជាតំបន់អីគេទៀត?

វ៉ែន ៖ ពីដើមសមរភូមិហើយ តំបន់ប្រទាញប្រទុងហើយ ខ្មែរក្រហមនៅម្ខាង រដ្ឋកម្ពុជានៅម្ខាង ។

ឈុនលី ៖ ខ្ញុំឮថាដូចមានគេជីកទំនប់មួយនៅម៉ក់ហឹន?

វ៉ែន ៖ អានឹងគេជីក ។

ឈុនលី ៖ ពេលណា?

វ៉ែន ៖ អាគេជីកថ្មីមិនដឹងគេ ។

ឈុនលី ៖ ជំនាន់ពតឆ្នាំមានអត់?

វ៉ែន ៖ បាទ!មាន ។

ឈុនលី ៖ គេឲ្យជីក?

វ៉ែន ៖ ប៉ុលពតជីកច្រើនណាស់រឿងទំនប់ ។

ឈុនលី ៖ ចុះអ៊ំដែលជីកនៅនឹង?

វ៉ែន ៖ ខ្ញុំអត់ទេ ចុះខ្ញុំទ័ព ខ្ញុំអត់មានទៅនៅមូលដ្ឋាននឹងផង ខ្ញុំមានតែលើកភ្លឺស្រែនៅរតនគីរី...។

ឈុនលី ៖ អ៊ំថាស្រុកអីគេ?

វ៉ែន ៖ ស្រុក បរកែវ បានលុង ។

ឈុនលី ៖ ដល់ពេលនៅនេះអីចឹង ច្បាំងយូរទេ?

វ៉ែន ៖ យូរវ៉ៃជាមួយយួន ។

ឈុនលី ៖ បានន័យថាតំបន់១០២នេះ ឆ្នាំ៧៩មានប៉ាវ៉ានៅនឹងទៀត?

វ៉ែន ៖ អត់មានទេ មានតែខ្មែរក្រហមទេ ប៉ាវ៉ានៅខាងប៉ោយប៉ែត ខាងអូរជ្រៅ ។

ឈុនលី ៖ តំបន់ចាប់ពីណាមកគេហៅ១០២?

វ៉ែន ៖ ចាប់ពីខ្វាងបាប់មក ខាងនេះប៉ោយប៉ែតមកហៅអូរជ្រៅ ចាប់ត្រឹមអូរជ្រៅមកនឹង ប៉ោយប៉ែតអូរជ្រៅ ។

ឈុនលី ៖ អ៊ំថាដាក់មីនអីចឹង ខាងនឹងខ្មែរក្រហមអ្នកដាក់?

វ៉ែន ៖ ខ្មែរក្រហមអ្នកដាក់ ។

ឈុនលី ៖ ចាប់ផ្ដើមពីឆ្នាំណាដាក់មីន?

វ៉ែន ៖ ដាក់ឆ្នាំ៨០ ។

ឈុនលី ៖ ពេលនឹងវៀតណាមចូលមកដែរ?

វ៉េន ៖ ចូល វ៉ៃគ្នា ។

ឈុនលី ៖ ហើយវៀតណាមគេដាក់មីនអត់?

វ៉េន ៖ វៀតណាមគេដាក់ខាងតំបន់គេ ខាងគេកាន់កាប់ ខ្មែរក្រហមដាក់ខាងខ្មែរក្រហមកាន់កាប់ទៅ ។

ឈុនលី ៖ ច្បាំងគ្នាយូរទេ មុននឹងអ៊ំបានទៅថៃ?

វ៉េន ៖ វាយូរតាំងពីយើងវ៉ៃឆ្នាំ៨០នឹងមក វ៉ៃមករហូតមកទល់នឹងអ៊ុនតាក់នឹង ។ អ៊ុនតាក់ចូលហើយ យើងសំរុះសំរួលអត់ត្រូវរូវគ្នានៅវ៉ៃទៀត ។

ឈុនលី ៖ ៩០ជាងនឹង?

វ៉េន ៖ បាទ! វ៉ៃនឹងហើយ ។

ឈុនលី ៖ ចុះអ៊ំថាទៅទឹកដីថៃឆ្នាំណា?

វ៉េន ៖ ទៅអាឆ្នាំ៨៥ យួនវ៉ៃចូលមកម៉ាឡៃឡើងខ្ទេចយើងរត់ចោលអស់ ឃើញសារតាំងសម្តេចសីហនុ សារតាំងគាត់នៅកន្លែងភូមិដូងសម្តេចសីហនុគាត់មកនៅនឹងដែរ ។

ឈុនលី ៖ នៅឆ្នាំណា?

វ៉េន ៖ មិនដឹងនៅឆ្នាំណាទេ ខ្ញុំភ្លេចអស់ហើយ ធ្វើសារតាំងជូនសម្តេចនឹង ដែលកាលនឹងគេអ្នកជប៉ុនអីគេ ហើយពួកកូរ៉េប្រគល់សារតាំងនៅអង្គការសហប្រជាជាតិឲ្យសម្តេច ប៉ុនគេអត់ប្រគល់នៅដីថៃ គេមកប្រគល់នៅដីខ្មែរ ។ ហើយដីខ្មែរគ្មានកន្លែងណាធ្វើការពារសន្តិសុខអត់បាន មានតែម៉ាឡៃនឹងការពារសន្តិសុខបានធ្វើសារតាំងសម្រាប់ថ្វាយស្តេច ។

ឈុនលី ៖ ឆ្នាំណា?

វ៉េន ៖ បើមិន៨២ ៨៣ គេរើសសារតាំង ។

ឈុនលី ៖ ពេលនឹងសម្តេចសីហនុគាត់រត់មកនឹងយូរ?

វ៉េន ៖ គាត់មកនឹងមួយភ្លែតៗ គាត់នៅប៉េកាំង គាត់គ្រាន់មកទទួលសារតាំងគេប្រគល់ឲ្យអង្គការសហប្រជាជាតិនឹង ។

ឈុនលី ៖ ចុះអ៊ំរត់ទៅដីថៃនឹង នៅតំបន់ជំរំអីគេ?

វ៉េន ៖ នៅគេហៅជំរំសែនៗនៅភ្នំខៀវ គេហៅជំរំភ្នំខៀវ ។

ឈុនលី ៖ ភ្នំខៀវនៅណា?

វ៉េន ៖ ភ្នំខៀវយើងដាក់គ្នាយើង គេហៅជំរំ៨៥ យើងរត់ពី៨៥ទៅដល់ដាក់ឈ្មោះ៨៥ ។

ឈុនលី ៖ ឈ្មោះនឹងដោយសារតែពួកយើងរត់នេះទៅ?

វ៉ែន : ហ្អឺហើយ រត់ចេញពីនេះទៅនៅអាឆ្នាំ៨៥នឹង បានដាក់ជំរំ៨៥ ។

ឈុនលី : កាលនឹងអ៊ំមានគ្រួសារនៅ?

វ៉ែន : ខ្ញុំមានហើយ ខ្ញុំគេសុំរៀបការតាំងពីឆ្នាំ៨០ ។

ឈុនលី : ចុះអ៊ំស្រីគាត់ធ្វើស្អី?

វ៉ែន : កងដឹកជញ្ជូន ។

ឈុនលី : ដែលក្រោមការដឹកនាំរបស់យាយហៀងនឹង?

វ៉ែន : បាទ! យាយហៀងនឹងគាត់ក្រោយមកទេ ពីមុនយាយវ៉ាទ យាយឡៃ យាយលេង នៅប៉ុន
គាត់មានគ្រួសារអស់ហើយ ។

ឈុនលី : នៅណា?

វ៉ែន : នៅខាងអូរស្រឡៅ ។

ឈុនលី : គាត់នៅភូមិអូរស្រឡៅ?

វ៉ែន : បាទ!

ឈុនលី : ដល់យាយហៀងនៅភូមិដូង?

វ៉ែន : បាទ!

ឈុនលី : ដល់ពេលនៅដីថៃយើងនៅចេញចូល?

វ៉ែន : ចេញចូលបានយើងមកវ៉ៃតស៊ូចេញចូលបាន ទាហានថៃវាឲ្យយើងចេញចូល ចុះយើងអ្នក
តស៊ូ គេមានហាមឃាត់អី ។

ឈុនលី : ចុះដល់ពេលចេញពីថៃវិញឆ្នាំណា?

វ៉ែន : ចេញពីថៃមកឆ្នាំ៩០ ។

ឈុនលី : ចេញមកអស់គ្នាអត់?

វ៉ែន : អស់ យើងរំដោះទ័ពគេវ៉ៃតាមនេះបាន រំដោះបានយើងបញ្ជូនប្រជាជនមកវិញ ។

ឈុនលី : ចុះខ្ញុំឮអ្នកខ្លះគាត់ថា៩៣?

វ៉ែន : ៩៣អ៊ុនតាក់នឹងហើយ ឆ្នាំ៩០មកវិញហើយបញ្ជូនមកនេះ ខ្ញុំដាច់ដៃនឹងចូលពីដីថៃមកវិញ ។

ឈុនលី : ៩០?

វ៉ែន : បាទ!

ឈុនលី : ម៉េចបានអីចឹង?

វ៉ែន : ផ្ទុះមីនមកតាមនេះ គ្មានអ្នកណាហ៊ានចូលទេ ។ ប៉ុន្តែខ្ញុំមកមុនគេ ខ្ញុំនៅតាំងពី៧៩ ខ្ញុំដឹងដីខ្ញុំៗ
ចាំរហូតដីសព្វថ្ងៃនេះ ដីនេះសុទ្ធតែមីនយួនដាក់ ហើយខ្ញុំមកបងសាម៉ានគេឲ្យខ្ញុំអាររណៅធ្វើ

មន្ទីរពេទ្យធ្វើផ្ទះក្បៀវធ្វើសាលារៀននៅភូមិដូងនេះ ព្រោះខ្ញុំធ្វើបានម៉ាចប់ ខ្ញុំអត់ចេះទាស់អីទេៗ ហើយដល់អីចឹងគេមកដេកអារឈើនឹងៗ គម្រោងការគេជម្លៀសយកប្រជាជនពីដីថៃមកនៅដីខ្មែរវិញ ។ ដល់អីចឹងឈ្មោះខ្ញុំអន្តភាពខ្ញុំត្រូវនៅភូមិដូង នៅជាមួយបងសាម៉ន ប៉ុនដល់ខ្ញុំអត់មកនៅជាមួយគាត់ ខ្ញុំសុខចិត្តមកនៅដីចាស់ខ្ញុំពី៧៩ ។ ខ្ញុំអត់សុខចិត្តនៅជាមួយមេទេ ខ្ញុំសុខចិត្តមកនៅជាមួយប្រជាជន ហើយគេអត់ទទួលស្គាល់ខ្ញុំទេ គេថាយើងមិនស្តាប់មេមិនស្តាប់កើយ ។ ខ្ញុំថាឲ្យដីខ្មែរ អ្នកណាស្គាល់មិនស្គាល់ អ្នកណាឲ្យអង្ករអញស៊ីមិនឲ្យហីទៅដីខ្មែរ អញនៅកន្លែងក៏បាន សិទ្ធិរបស់អញ ។

ឈុនលី ៖ យើងវ្គាររដី?

វ៉ែន ៖ ខ្ញុំអត់ទាន់ហ៊ានវ្គាររទេ ដុតសិន ដុតព្រៃផ្ទះម៉ាយប់ម៉ាថ្ងៃផ្ទុះមីន ។

ឈុនលី ៖ ពេលដុតនឹងផ្ទុះតែម្តង?

វ៉ែន ៖ ផ្ទុះ ។

ឈុនលី ៖ ម៉េចអីចឹង?

វ៉ែន ៖ មីនវានៅលើ ព្រៃវាក្តៅខ្លាំង ។

ឈុនលី ៖ ក្តៅផ្ទុះ?

វ៉ែន ៖ ក្តៅផ្ទុះហើយ ។

ឈុនលី ៖ ផ្ទុះខ្លាំង?

វ៉ែន ៖ ផ្ទុះឡើងល្បី បងសាម៉នគេស្តទៅប្រាប់ប្រពន្ធខ្ញុំនៅដីថៃថាមិនដឹងម៉េចទេអាវ៉ែន ផ្ទុះមីនម៉ាថ្ងៃហើយ ។

ឈុនលី ៖ បានអីគេស្ត?

វ៉ែន ៖ គេអូ គេនិយាយតាមគេអូអាសេ២៥ ។

ឈុនលី ៖ មើលទៅអ៊ំជិតស្និតជាមួយពូសាម៉ននឹង?

វ៉ែន ៖ ចឹមិនស្និតបើខ្ញុំចេះអន្លែលគាត់ ខ្ញុំមិនមែនចេះនិយាយៗ ខ្ញុំប្រាប់គាត់ចូលចិត្តខ្ញុំណាស់ ។

ឈុនលី ៖ ម៉េចបានអីចឹង?

វ៉ែន ៖ ចុះខ្ញុំទ័ពជើងចាស់ កម្រមានណាស់ អត់មានអ្នកណាដូចខ្ញុំបានទេ និយាយខ្ញុំអត់ចេះឃើញទេ ដែលខ្ញុំប្រឡំលាក់តែថ្នាក់ដឹកនាំខ្ញុំស្គាល់ទាំងអស់ ។

ឈុនលី ៖ អ៊ំអាចជួយរៀបរាប់បានទេ តួនាទីគាត់ គាត់ឈ្មោះអីខ្លះ អ្នកណាខ្លះថ្នាក់ដឹកនាំនៅនេះដំបូងគេបង្អស់?

វ៉ែន ៖ ហ្នឹងហើយមុនដំបូងគេមានខ្មោចតាជួតនឹងៗគាត់អ្នកការប្រពន្ធឲ្យខ្ញុំ ។

ឈុនលី ៖ គណៈតំបន់ តាំងពី៧៩?

វ៉ែន ៖ បាទ!

ឈុនលី ៖ ឥឡូវគាត់ស្លាប់ហើយ?

វ៉ែន ៖ គាត់ស្លាប់ហើយ បានឡើងខ្មោចតាយ៉ែមៗនេះគាត់ឡើងទី២ ។

ឈុនលី ៖ អឺថា៨០ ៨១?

វ៉ែន ៖ បាទ! ហើយខ្មោចតាយ៉ែមនេះស្និតជាមួយខ្ញុំទៀត ចុះគាត់ហៅខ្ញុំទៅធ្វើផ្ទះ អារឈើធ្វើឃ្លាំង ធ្វើសាលារៀនអីនឹង ផ្ទាល់នៅជាមួយគាត់នឹងទៀត ។ ការពិតគាត់ចង់បណ្តុះខ្ញុំណាស់ ។

ឈុនលី ៖ ចង់បណ្តុះឲ្យអី?

វ៉ែន ៖ គាត់បណ្តុះហៅខ្ញុំទៅរៀនអក្សរ រៀននយោបាយរាល់ថ្ងៃ តែខ្ញុំវាហត់ពេកទម្រាំតែធ្វើការហត់ពេកខ្ញុំទទួលអត់បាន អត់មានម៉ោងសម្រាកទេ ។ ខ្ញុំខឹង ខ្ញុំទ្រាំមិនបាន ខ្ញុំថាឲ្យគាត់វិញ ពូជខ្ញុំមិនមែនពូធ្វើគ្រូបង្រៀនទេ ដល់ថ្នាក់ហត់ពេក ។ ចុះម៉ោង៦រៀនដល់ម៉ោង៩៨យប់ ។

ឈុនលី ៖ ៦ព្រឹក?

វ៉ែន ៖ ៦ល្ងាចនោះ ហូបបាយហើយនោះទល់ម៉ោង៩យប់សម្រាក ហើយថ្ងៃឡើងព្រឹកឡើងអារឈើធ្វើសាលារៀន ធ្វើឃ្លាំង ធ្វើមន្ទីរពេទ្យ ធ្វើផ្ទះភ្ញៀវម៉ាចប់ ហើយណាមួយប្រពន្ធកូនមិនហត់មនុស្សគ្មានអ្នកណាដោះស្រាយមានតែម្នាក់ឯង ។

ឈុនលី ៖ ចុះដល់ពេលតាយ៉ែមនឹងហើយ បានពីណាគេទៀត?

វ៉ែន ៖ បានឈឹម មុនីនេះគាត់ផ្តាច់ខ្លួន ។

ឈុនលី ៖ ស្និតជាមួយអឺ?

វ៉ែន ៖ អត់ទេ អត់ស្និតទេពីព្រោះគាត់មកពីខាងកងទ័ព អ្នកចាត់តាំងកងទ័ពនៅកន្លែងនោះឲ្យធ្វើគណៈស្រុកណា ចៅហ្វាយស្រុក ស្គាល់ដែលមិនមែនមិនស្គាល់ទេ ។

ឈុនលី ៖ ម៉េចទៀត?

វ៉ែន ៖ បានបន្តមក ។

ឈុនលី ៖ មូលហេតុដែលអឺពិការ?

វ៉ែន ៖ អានឹងពិការខ្ញុំដោះមីន ដូចខ្ញុំនិយាយអីចឹង ។

ឈុនលី ៖ ដោះមីនរកដីនៅ?

វ៉ែន ៖ ដោះមីនកន្លែងនៅ ដីនៅ ។

ឈុនលី ៖ ហើយដើម្បីឲ្យប្រជាជន?

វ៉ែន ៖ ហ៊ឺ! អានឹងយើងដោះស្រាយតាមកន្លែងដីយើង ។

ឈុនលី ៖ ពេលមកពីថៃនឹងអ្នកណាចង់នៅប៉ុនណា ដោះមីនខ្លួនឯង?

វ៉ែន ៖ បាទ! អត់ទេ មិនមែនចង់ចាប់បានប៉ុនណាបានប៉ុននឹង គេកំណត់ឲ្យដីភូមិនឹងពីតែក្បាល៤០ បណ្តោយ៤០ កំណត់ម៉ាវ៉ែ ។

ឈុនលី ៖ ម៉ាគ្រួសារម៉ាវ៉ែ?

វ៉ែន ៖ ហ្នឹងហើយគ្រួសារម៉ាវ៉ែៗ ហើយខ្ញុំអត់ហ៊ានយកច្រើន ព្រោះខ្ញុំមានប្រវត្តិតាំងពី៧៩នោះ ប្រវត្តិលោក...គ្មានអ្នកណាមានដីច្រើនជាង អា៧៩ ។ គេនាំគ្នាអារឈើយកទៅលក់ឲ្យថៃ ខ្ញុំអត់ទេ ខ្ញុំកាប់ព្រៃធ្វើចំការ ។ ដល់អីចឹងខ្ញុំបានដីច្រើនៗ ដល់គេមានផែនការចែកដីប្រជាជន ធ្វើចំការធ្វើអីនឹង យកដីខ្ញុំម៉ាវាល ខ្ញុំអត់ឲ្យៗគេថាខ្ញុំលោភដី ។ ខ្ញុំលោភម៉េច ថាលោភក៏ថាបានព្រោះខ្ញុំកាប់តាំងពីដីនៅព្រៃ ហើយដល់ធ្វើវាលបានយករបស់ខ្ញុំទៅចែកខ្ញុំម៉េចឲ្យ ។

ឈុនលី ៖ ហើយគេសុខចិត្ត?

វ៉ែន ៖ អត់ ខ្ញុំអត់ឲ្យធ្វើអីខ្ញុំៗថាមិនឲ្យៗ ។

ឈុនលី ៖ អ្នកណាអ្នកចែក?

វ៉ែន ៖ មេអគ្គភាព ដូចមេភូមិមេអី ។

ឈុនលី ៖ កាលនឹងអ្នកណាមេភូមិដូង?

វ៉ែន ៖ មេភូមិដូងមុនដំបូងតាជាៗ ហ៎! មេភូមិដូងគាត់នៅនោះផ្សេងទេ អានឹងគេចែកភូមិគ្នាហើយ ភូមិដូងនោះផ្សេង ភូមិសន្តែផ្សេង ។

ឈុនលី ៖ បើគិតទៅអាភូមិដូងដែលមកនៅដំបូង ដែលអ៊ំថាមានតែភូមិដូងនឹងមួយ?

វ៉ែន ៖ បាទ! ភូមិដូងនឹងមួយ ។

ឈុនលី ៖ អ្នកណាអ្នកកាន់ភូមិដូង?

វ៉ែន ៖ ភូមិដូងអត់ទាន់មានទេ អត់ទាន់មានមេភូមិ ។

ឈុនលី ៖ អត់ទាន់មានមេភូមិអីត្រឹមត្រូវ?

វ៉ែន ៖ អត់មានទេ គ្រាន់ស្វារគេទេ គេដាក់ស្វារភូមិដូងកន្លែងចែកអន្តរពីដើម គ្រាន់តែប៉ុននឹង ។

ឈុនលី ៖ នៅផ្ទះអ៊ំដំបូងដែលមកនៅនឹងនៅណា?

វ៉ែន ៖ នៅមាត់អូរនឹង ។

ឈុនលី ៖ ចុះមកនៅនេះពេលណា?

វ៉ែន ៖ ឆ្នាំ៨០ ខ្ញុំការហើយៗមកនៅនឹង ។

ឈុនលី ៖ ចុះមកនៅមាត់អូរនឹងយើងខំកាប់ឆ្ការហើយយើងទៅនៅកន្លែងផ្សេងទៀត?

វ៉ែន ៖ អានឹងទាល់តែរត់យួន៨៥នឹង បានចេញពីនឹងទៅម៉ង ។

ឈុនលី ៖ មកនៅណា?

វ៉េន ៖ អាឆ្នាំ៨៥នឹងវត់ទៅដីថៃ។

ឈុនលី ៖ មកវិញ?

វ៉េន ៖ មកវិញចូលមកនៅផ្ទះចាស់វិញ។

ឈុនលី ៖ មាត់អូរនឹង?

វ៉េន ៖ បាទ! អានេះទើបមកនៅក្រោយ គេទើបនឹងធ្វើផ្លូវនេះ ពីដើមផ្លូវនៅមាត់អូរ អាផ្លូវនេះធ្វើម៉ាហឹកពួក...ថៃវាចូលមកដឹកឈើ។

ឈុនលី ៖ អ៊ំពិការហើយ អ៊ំឈប់ធ្វើទ័ព?

វ៉េន ៖ ឈប់ហើយ យើងពិការប៉ុននៅដឹកជញ្ជូនៗ។

ឈុនលី ៖ ទៅជាមួយគ្រួសារអ៊ំ?

វ៉េន ៖ អត់ទេ គ្រួសារនៅផ្ទះ ទៅតែខ្ញុំ។

ឈុនលី ៖ ចុះម៉េចក៏គាត់អត់ធ្វើការ?

វ៉េន ៖ ប្រពន្ធ ចុះយើងមានគ្រួសារហើយយើងធ្វើអីទៀត មានដឹកជញ្ជូនអីទៀត ដឹកជញ្ជូនសម្រាប់តែអ្នកនៅលីវទេ អានឹងត្រូវដឹកជញ្ជូនយកឲ្យកងទ័ព ដឹកគ្រាប់ដឹកអីជញ្ជូនគ្រាន់។

ឈុនលី ៖ ចុះបានពេទ្យណាព្យាបាល?

វ៉េន ៖ ពេទ្យគេមានពេទ្យគេអង្គភាព ពេទ្យៗភូមិដូងនឹងពេទ្យធំគេនឹង ជំនិតគេមកពីចិនទៅរៀនចិន។

ឈុនលី ៖ អ៊ំស្គាល់អ្នកណាគេអ្នកគ្រប់គ្រងខាងពេទ្យ?

វ៉េន ៖ ប្រធានពេទ្យជំនាន់នឹងតាអីដាច់អាណត្តិឥឡូវឈ្មោះចុងៗមាត់ វា២-៣ដំណាត ពីដើមគេហៅយាយហ៊ាងៗផ្សេងទៀត យាយហ៊ាងខាងពេទ្យមិនមែនយាយហ៊ាងខាងដឹកជញ្ជូន មិនមែននារីនោះ ហ៊ាងនេះផ្សេងទៀត។ ប៉ុនប្រធានពេទ្យនឹងមិនមែនយាយហ៊ាងនឹងទេ គាត់ចេះវៀតណាម គាត់ចេះបកប្រែ ពេលចាប់វៀតណាមបាន ហៅគាត់ទៅបកប្រែយាយហ៊ាងនឹង។ អូ! យាយកេងៗយើងសព្វថ្ងៃនឹង។

ឈុនលី ៖ គាត់នៅរស់ដែរ?

វ៉េន ៖ បាទ!នៅឥឡូវក៏គាត់នៅតែក្អាប់ យាយកេងនឹង។

ឈុនលី ៖ គាត់នៅណា?

វ៉េន ៖ នៅភូមិដូង។

ឈុនលី ៖ ភូមិដូងសព្វថ្ងៃ?

វ៉េន ៖ បាទ!

ឈុនលី ៖ ឃុំម៉ាឡៃ?

វ៉ន ៖ ឃុំម៉ាឡៃ ។

ឈុនលី ៖ យាយគេឯប្រធានពេទ្យ?

វ៉ន ៖ ប្រធានពេទ្យ ។

ឈុនលី ៖ បន្ទាប់មកអ៊ំខាងដឹកជញ្ជូនវិញ កាលនឹងច្បាំងគ្នាខ្លាំង?

វ៉ន ៖ នៅ ច្បាំងគ្នារ៉ៃគ្នារហូត ។

ឈុនលី ៖ ដល់ពេលណា?

វ៉ន ៖ ដល់ពេលអា៩៣ផ្ដាច់ខ្លួននឹងបានកាត់បន្ថយការរ៉ៃហើយ ដឹកជញ្ជូនក៏កាត់បន្ថយដែរ ។

ឈុនលី ៖ ដូចមិនមែន៩៣?

វ៉ន ៖ ខ្ញុំថា៩៣ផ្ដាច់ខ្លួន ។

ឈុនលី ៖ ផ្ដាច់ខ្លួន២ដង?

វ៉ន ៖ អត់ទេ ។

ឈុនលី ៖ ផ្ដាច់ខ្លួនលែងច្បាំងគ្នាទៀត?

វ៉ន ៖ លែងហើយអានឹង ។

ឈុនលី ៖ ចុះក្រោយមកអ៊ំធ្វើអីទៀត?

វ៉ន ៖ ធ្វើអីទេ ខ្ញុំនៅប្រជាជន ។

ឈុនលី ៖ ឈប់ដឹកជញ្ជូនដឹកអី?

វ៉ន ៖ អត់ទេ ដាច់ហើយ យើងឈប់រ៉ៃគ្នាហើយ ដូចយើងផ្ដាច់ខ្លួននេះគ្មានទៅរ៉ៃអីទៀត នៅស្រងំកន្លែងរៀង១ខ្លួនមុខសញ្ញាខាងនេះត្រឹមប៉ុនម៉ាន ខាងរដ្ឋនោះកម្ពុជា ការពារតែគាត់កម្ពុជាទៅអានឹងយើងទំនាក់ទំនង ។

ឈុនលី ៖ អ៊ំថាស្រុកម៉ាឡៃបង្កើតនៅពេលក្រោយផ្ដាច់ខ្លួន?

វ៉ន ៖ អានឹងឈ្មោះពេលផ្ដាច់ខ្លួនហើយបានគេដាក់ឈ្មោះអឺចឹង បានបង្កើតស្រុក ការយើងផ្ដាច់ខ្លួនហើយយើងចូលរដ្ឋកម្ពុជាហើយគេបង្កើតតំបន់ គេហៅដូចបង្កើតខេត្តបន្ទាយមានជ័យមិនរៀបចំស្រុកដាក់ឈ្មោះស្រុកម៉ាឡៃ ។

ឈុនលី ៖ ដល់ពេលនឹងលោកឈឹម មុនីនឹង?

វ៉ន ៖ បាទ! គេចាត់តាំងលោកឈឹម មុនីនឹងឲ្យធ្វើចៅហ្វាយស្រុក ព្រោះគាត់អ្នកដឹកនាំចាស់ដែរ ហើយសម្ដេចហ៊ុន សែនគាត់ថាអ្នកណាតំណែងនឹងឲ្យនៅនឹងដដែល អត់ដកអីទៅណាទេ របស់របរអីនៅទាំងអស់

ឈុនលី ៖ គាត់ចៅហ្វាយស្រុកដល់ពេលណា?

វ៉េន ៖ ពេលដែលបោះឆ្នោតអាណត្តិទី១ បោះឆ្នោតជីង៩០ប៉ុន្មានទេ ។

ឈុនលី ៖ ៩៣?

វ៉េន ៖ បាទ!អានឹងគាត់ធ្វើចៅហ្វាយស្រុកទេ ដល់អាណត្តិទី២នេះបានដូរៗដាក់ ទេព ខុនណាល់វិញ ។

ឈុនលី ៖ អីកាលនឹងដែលពូឈ្មោះលោក ទេព ខុនណាល់ នឹងទេ?

វ៉េន ៖ អត់ទេ ទេព ខុនណាល់ នឹងទើបមកក្រោយ ខ្ញុំទើបនឹងជីងឥឡូវដែរទេ គាត់ដៃស្ដាំរបស់ប៉ុលពត ។

ឈុនលី ៖ នៅជំនាន់ពាន្ឆាំគាត់នៅណា?

វ៉េន ៖ គាត់នៅជាមួយប៉ុលពតរហូត ។

ឈុនលី ៖ នៅភ្នំពេញ?

វ៉េន ៖ បាទ! ខ្ញុំអត់ដែលឃើញទេចៅហ្វាយស្រុក ទេព ខុនណាល់នឹង ។

ឈុនលី ៖ ម៉េចបានអីជីងគាត់?

វ៉េន ៖ ជីងគាត់ ជីងតាមរយៈ គាត់ជំនិតប៉ុលពតផ្ទាល់ ហើយប៉ុលពតស្លាប់នឹង ឲ្យចៅហ្វាយស្រុកនេះយកប្រពន្ធប៉ុលពតនេះទៀត ។

ឈុនលី ៖ គាត់ផ្ដាំ?

វ៉េន ៖ បាទ! ឲ្យយកប្រពន្ធគាត់ ។

ឈុនលី ៖ អ្នកណាគេប្រាប់អីបានជីងរឿងច្រើន?

វ៉េន ៖ អត់ទេ ត្រូវតែជីង លាក់ម៉េចជិត ព្រោះយើងហៅថាចរន្តការងារត្រូវតែមានអត់ចោលបានទេ ស្អីក៏ត្រូវតែជីងដែរ ។

ឈុនលី ៖ ចុះការនឹងគេលាក់ការណ៍?

វ៉េន ៖ លាក់សម្រាប់តែកន្លែងអ្នកលាក់ទេ អ្នកត្រូវលាក់គេលាក់ តែមិនត្រូវលាក់ កន្លែងយើងនិយាយៗហើយ លាក់ម៉េចជិត ដំណាក់កាលដល់ក្រឡាត្រូវបើកត្រូវស្រាយ លាក់ម៉េចក៏មិនជិតដែរ ។

ឈុនលី ៖ កាលអីពិការហើយ យើងនៅខាងដឹកជញ្ជូន យើងទទួលបានស្បៀងអីគ្រប់គ្រាន់ទេ?

វ៉េន ៖ គ្រប់គ្រាន់ ។

ឈុនលី ៖ មានសល់ខ្លះទេ?

វ៉េន ៖ សល់ ហូបម៉េចអស់ចិញ្ចឹមជ្រូក ចិញ្ចឹមអីលក់ អន្ទរ ។

ឈុនលី ៖ កាលនឹងមានជ្រូកទៀត?

រ៉េន ៖ មាន ជ្រូកទិញពីថៃ ។

ឈុនលី ៖ យកទៅលក់ឲ្យអ្នកណាគេ?

រ៉េន ៖ ចិញ្ចឹមលក់ឲ្យខ្មែរគ្នាយើង កាប់លក់ ខ្ញុំក៏អ្នកកាប់ជ្រូកដែរជំនាន់នឹង ។

ឈុនលី ៖ បើគិតទៅគេចាយលុយពេលណា?

រ៉េន ៖ ចាយលុយតាំងពីអ្នកណានៅព្រំដែននេះ អ្នកណារកលុយបាន អ្នកនឹងចាយទៅ ចាយលុយថៃមិនមែនចាយលុយខ្មែរ ។

ឈុនលី ៖ ចូលព្រំដែនឆ្នាំ៧៩?

រ៉េន ៖ បាទ!

ឈុនលី ៖ ចាប់ផ្ដើមចាយលុយ?

រ៉េន ៖ ចាយលុយថៃ ។

ឈុនលី ៖ ពេលនឹងខ្មែរក្រហមកាប់ព្រៃកាប់អីកាប់អីលក់?

រ៉េន ៖ បាទ! គេអារឈើអារអីលក់ឲ្យថៃ យកលុយចាយ លក់អង្ករកាកបាទចែកហូបអត់អស់យើងលក់ ត្រីខត្រីអី ។

ឈុនលី ៖ អ៊ំទស្សរាប់ទៅលេងស្រុកកំណើតវិញ ដល់ឥឡូវ?

រ៉េន ៖ ទៅ ខ្ញុំទៅកាលអ៊ុនតាក់ ។

ឈុនលី ៖ ៩៣?

រ៉េន ៖ បាទ!

ឈុនលី ៖ ហើយទៅដឹបូង បងប្អូនគាត់ដឹងទេ?

រ៉េន ៖ អូ! ខ្ញុំទៅលួចលាក់ កាលនឹងនៅខាងរដ្ឋកម្ពុជា ។

ឈុនលី ៖ ហើយទៅដំបូងម៉េច?

រ៉េន ៖ ទៅគេត្រេកក្បាលគ្រប់គ្នា គេថាមិនសមនឹងរស់ ។ ចុះមើលខ្ញុំអត់បានទៅស្រុកតាំងពីឆ្នាំ៧៥រំដោះភ្នំពេញនឹងហើយមក ។ អាឆ្នាំរំដោះភ្នំពេញនឹងអត់បានទៅលេងផ្ទះទៀត ម៉ែខ្ញុំអត់បានដឹងថាខ្ញុំនៅរស់ផង ដល់ខ្ញុំទៅអ៊ុនតាក់នេះភ្ញាក់ខ្លួន បានដឹងកូនឯងនៅរស់ ។

ឈុនលី ៖ គាត់ដឹងថាអ៊ំចូលជាមួយខាងខ្មែរក្រហម?

រ៉េន ៖ ប៉ីគាត់មិនដឹង គាត់ដឹង ខ្ញុំចូលមក ខ្ញុំប្រាប់គាត់ដែរ ប៉ុនគាត់លួចចូលទេ សុំគាត់ចូលគាត់អត់ឲ្យផ្ញើ គាត់ថាអត់មានអ្នកណានៅជាមួយគាត់ ។

ឈុនលី ៖ ពេលណា?

វ៉េន ៈ អាឆ្នាំ៧០នឹង ។

ឈុនលី ៈ ហើយដល់ពេលអាំទៅស្រុកភូមិ អ្នកភូមិអ្នកខាងអីគេ?

វ៉េន ៈ អត់ទេ អត់មានអីដែរ ។

ឈុនលី ៈ ទឹងគេអីចឹង?

វ៉េន ៈ អត់ទេ អត់ទឹង គេមានទទួលស្វាគមន៍អាយុវែង ផាប់ណាស់ភូមិខ្ញុំអាជំនាន់ខ្ញុំ ។

ឈុនលី ៈ អ្នកដែលចូលនឹង?

វ៉េន ៈ អ្នកដែលចូលនឹងផាប់ខ្មេច ។

ឈុនលី ៈ ភាគច្រើនគាត់ស្លាប់នៅពេលណា?

វ៉េន ៈ ស្លាប់ពេលសង្រ្គាមនឹង អាវៀត្នានឹង ។

ឈុនលី ៈ ៧០ប៉ុន្មាន?

វ៉េន ៈ ចុះយើងគិតមើលតាំងពី៧០ទល់៧៥ វៀត្នារហូត ។

ឈុនលី ៈ មុនជំនាន់៣ឆ្នាំ?

វ៉េន ៈ បាទ!៣ឆ្នាំនេះសម័យប៉ុលពតទេ ៣ឆ្នាំអានឹងគេហៅសម័យនយោបាយ មិនមែនសង្រ្គាមៗ គេហៅជំនាន់៥ឆ្នាំៗអានឹងជំនាន់ លន់ នល់ ។ ដល់សម័យ៣ឆ្នាំសម័យនយោបាយ អានឹង ប៉ុលពត ។

ឈុនលី ៈ ឥឡូវនឹងអាំធ្វើការងារអីខ្លះ?

វ៉េន ៈ អត់ទេ ខ្ញុំរកស៊ីចិញ្ចឹមជីវិតខ្លួនឯង ធ្វើចំការចិញ្ចឹមជ្រូក ចិញ្ចឹមអី ។

ឈុនលី ៈ បើតាមអាំធ្លាប់ឆ្លងកាត់កាលលើកមុនមានរបបបើក គេផ្តាច់របបពេលណា?

វ៉េន ៈ គេផ្តាច់របបខ្ញុំតាំងពី ខុសពីខ្ញុំគេនៅមានរហូត សព្វថ្ងៃក៏គេនៅមានដែរ ។ របបបំណាច់រដ្ឋ ឧបត្ថម្ភជនពិការ ហើយនឹងអ្នកចាស់ជរានៅមានគឺខ្ញុំមាន ប៉ុនត្រង់ខ្ញុំដូចខ្ញុំនិយាយ ដូចខ្ញុំ ជម្រាបប្អូនឯងពីដើមអត់រណបជាមួយមេ ដល់អីចឹងគេទឹងខ្ញុំ គេផ្តាច់ចោលតែម្តង ។

ឈុនលី ៈ ពេលណាចាប់ផ្តើមផ្តាច់មែនទែន?

វ៉េន ៈ តាំងពីមកៗពីថៃវិញ៩៣ ។

ឈុនលី ៈ មកពីថៃ៩៣ ឬ៩០?

វ៉េន ៈ អឺ! ៩០ ផ្តាច់ខ្ញុំមិនសូវចាំទេ កាលនឹងប្រជាជនគេកាត់ពីមន្ទីរឲ្យរកស៊ីខ្លួនឯង អត់មានចែក អង្ករឲ្យទៀតទេ អានឹងខាងប្រជាជន ប៉ុនបើខាងអ្នកពិការគេបាន ។

ឈុនលី ៈ តាមពិតអាំលែងមានឈ្មោះជាទ័ពពេលឆ្នាំ៩០នឹង?

រ៉ែន ៖ បាទ! ហ្នឹងហើយអស់ហើយ យើងនៅប្រជាជនវិញ យើងចេញពីកងទ័ព របបអីក៏គេអត់ឲ្យដែរ អត់មានខ្ញុំរកស៊ីតែខ្លួនឯង ។

ឈុនលី ៖ កាលជំនាន់នឹងមានកូនចូលរៀន មានសាលាទេ?

រ៉ែន ៖ អត់ទាន់មានទេ អត់ទាន់មានសាលាទេ ។

ឈុនលី ៖ សាលារៀនចាប់ផ្តើមមានពេលណា?

រ៉ែន ៖ ចុះមានពេលមកពីដីថៃវិញហើយ ៩១ ៩២ ។

ឈុនលី ៖ កាលនឹងកូនអ៊ំមានអាយុប៉ុន្មាន?

រ៉ែន ៖ ដឹងអាយុប៉ុន្មានទេ ។

ឈុនលី ៖ គាត់បានចូលរៀនទេ?

រ៉ែន ៖ រៀន វាអត់សូវយកចិត្តទុកដាក់រឿងឆ្នាំ ។

ឈុនលី ៖ ក្រោយមកអ៊ំរកស៊ីខ្លួនឯង ឬផ្តាច់របបអីចឹង ដូចថាមានការលំបាកខ្លាំង?

រ៉ែន ៖ ដូចខ្ញុំអត់សូវលំបាកប៉ុន្មានទេ ខ្ញុំរកស៊ីគោ ខ្ញុំជួញគោ ។

ឈុនលី ៖ ពីឆ្នាំណា?

រ៉ែន ៖ មុនអ៊ុនតាក់ ចាប់ផ្តើម ។

ឈុនលី ៖ ពិការភ្នែម?

រ៉ែន ៖ អត់ទេ តាំងពីអត់ទាន់ពិការ ។ ហ្នឹងហើយពិការហើយ មកពីដីថៃផ្ទុះមីនពិការហើយ បានគេបើកឲ្យប្រជាជនរកស៊ី យកគោយកជ្រូកអីពីក្នុងមកពីខាងរដ្ឋកម្ពុជាមកលក់ឲ្យថៃ ចាប់ផ្តើមបើកច្រកកស៊ី ។

ឈុនលី ៖ នៅពេលនឹង យើងបើកច្រករកស៊ី ប៉ុន្តែសង្គ្រាមនៅតែមាន?

រ៉ែន ៖ នៅតែមាន ទ័ពចេះតែវៃ អ្នកដឹកជ្រូកដឹកគោយកមកលក់ចេះដឹកមក ។

ឈុនលី ៖ ចុះកាលនឹងធួរធាដែរ?

រ៉ែន ៖ ធួរ ខ្ញុំធួរដែរខ្ញុំទិញឡានទិញអីបានមុនគេ ចុះខ្ញុំរកស៊ីគោ ។

ឈុនលី ៖ អ៊ំថាឆ្នាំណាគេប្រមូលដាក់?

រ៉ែន ៖ អានឹងតាំងពីមុននឹងទៀត ។

ឈុនលី ៖ ក្នុងឆ្នាំណា?

រ៉ែន ៖ អានឹងមុននឹងអ៊ុនតាក់ចូល ។

ឈុនលី ៖ មកពីថៃវិញនៅ?

វ៉េន ៖ មកហើយ មកពីថៃនឹង បានប្រជាជនរកស៊ីធ្វើចំការ មានលុយមានអីទិញមាស ទិញរទេះគោអីនឹង ។

ឈុនលី ៖ ពេលនឹងបានគេចាប់?

វ៉េន ៖ បាទ! មូលហេតុដែលគេដករទេះគោដកអីនឹង កាលណាទុករទេះគោ យើងអត់សូវទៅមុន ។

ឈុនលី ៖ អត់សូវទៅធ្វើទ័ព?

វ៉េន ៖ បាទ! អត់សូវច្រើន គិតតែពីអារឈើលក់ឲ្យថៃ គម្រោងគេ ហើយផែនការនឹងមិនមែនត្រឹមគម្រោងទេ ។ ជាផែនការដកមាសដកអីនឹង ដោយសារអីដោយសារកាលណាទុកមាសទៅយើងប្រជាជនមានបាន គេនិយាយអត់ស្តាប់អាង ប្រជាជនអាង ថាអញមានស៊ីដែលចង់អ្នកឯងឲ្យអង្ករស៊ី មិនទៅស៊ីក៏អត់ភ័យ ដល់អីចឹងគម្រោងគេអីចឹង ។ ដូចខ្ញុំនិយាយខាងដើមទាល់តែយើងមានស៊ីគ្រប់គ្រាន់ហើយ អត់គិតទេរបស់អ្នកណាឲ្យមក ហីទៅ អញដោះស្រាយខ្លួនឯងបានហើយ យើញទេលែងសូវស្តាប់គេ ។

ឈុនលី ៖ បើកគិតទៅ ទោះបីមានរបបហូបចុកគ្រប់គ្រាន់ ក៏យើងអត់ពេញចិត្តនឹងបែបនឹង យើងចង់រស់នៅបែបរកស៊ីខ្លួនឯង?

វ៉េន ៖ បាទ! អានឹងអើ ហើយខ្ញុំអត់ទៅខ្វល់ ខ្ញុំតាំងចិត្តថាពូជម៉ែខ្ញុំពីដើមក៏គ្មានអ្នកណាឲ្យអង្ករស៊ីដែរ

ឈុនលី ៖ គាត់ពីដើម រកស៊ីអីគេ ឪពុកម្តាយ?

វ៉េន ៖ ខ្ញុំកើតអត់ទាន់ឪពុកផង ឪពុកខ្ញុំស្លាប់ចោលតាំងពីខ្ញុំបានម៉ាខួបកន្លះ អត់ស្គាល់មុខឪពុកម៉េចនៅតែម្តាយ ។

ឈុនលី ៖ តែកាលនឹងគាត់ធ្វើអី?

វ៉េន ៖ ធ្វើស្រែចំការដែរនឹង ប៉ុនគ្រាន់ថាយើងមានចិត្តអត់រណប តែធ្វើខុសថាខុស នឹងមេភូមិជូនប្អូនមកនឹងអត់ត្រូវជាមួយខ្ញុំដែរ ។

ឈុនលី ៖ អត់ត្រូវម៉េច?

វ៉េន ៖ អត់ត្រូវគ្រាន់ថា គាត់ច្រើនឡុំៗ គាត់និយាយទៅអត់សូវពិតប្រាកដ ហើយប៉ះខ្ញុំមកអត់ហ៊ានមាត់ទេ សូម្បីតែមេឃុំក៏ខ្ញុំអត់ចេះខ្លាច ។

ឈុនលី ៖ គាចាន់ រិន?

វ៉េន ៖ ហ្នឹងហើយ ពីដើមគាត់ហើយនឹងដូចបងហើយនឹងប្អូន ខ្ញុំស្និតនឹងគ្នាណាស់ ការងារជួយគាត់រហូតប៉ុនគាត់ឡុំៗច្រើនពេក ខ្ញុំនៅមិនកើតទេ ។

ឈុនលី ៖ ចុះតាមេឃុំនឹងគាត់ឡើងពេលណា?

វ៉េន ៖ គាត់ឡើងពេលគេរៀបចំស្រុកនឹង រៀនចំឃុំ ។

ឈុនលី ៖ ពីដើមគាត់ធ្វើអី?

វ៉េន ៖ គាត់នៅខាងកងដឹកជញ្ជូនដែរ គាត់ទើបជនពិការជើងចូលមកនៅភូមិនឹង ។

ឈុនលី ៖ គាត់ពិការជើង?

វ៉េន ៖ បាទ! ពិការជើងនៅកន្លែងដីគាត់នឹង កាប់ព្រៃដីគាត់សុទ្ធតែមីន ។

ឈុនលី ៖ អ៊ំដូចថាអ្នកក្រោមកទៀត អ៊ំដែលឮដូចថាប្រជាជនធម្មតាគេនិយាយ គេស្អប់គេខឹងខ្មែរក្រហម?

វ៉េន ៖ អឺ! ចេះតែមានហើយ ចេះឮៗពេញមាត់ ប៉ុន្តែខ្ញុំថាចេះ ខ្ញុំទប់ស្កាត់បានច្រើនណាស់ កាលណាកន្លែងណា បើអ្នកណាច្រឡោតខ្លាំងនិយាយៗនឹង ខ្ញុំបំភ្លឺឲ្យ ។

ឈុនលី ៖ ថាម៉េចៗទៅ?

វ៉េន ៖ រឿងខ្មែរក្រហមមិនមែនខ្មែរក្រហមទាំងអស់ ខ្មែរក្រហមវាខ្មែរក្រហម ក៏ប៉ុន្តែគ្មានអ្នកណាទៅសម្លាប់ប្រជាជនទាំងអស់ យើញអត់វាដោយបុគ្គលតើ ។ បើថាប៉ុលពតៗតែម្នាក់ឯងហើយឥឡូវពួកខ្ញុំអីនេះ យើងមកស្អប់គ្នាធ្វើអី ដឹងអីគ្នា ។ បើដូចខ្ញុំធ្វើខ្មែរក្រហមមែន ប៉ុនខ្មែរក្រហមចាប់ដាក់គុកប៉ុន្មានឆ្នាំ ។ អានឹងមូលហេតុអី យើញទេខ្ញុំនៅជាមួយខ្មែរក្រហម ប៉ុនខ្មែរក្រហមចាប់ដាក់គុកដែរ អានឹងជារឿងរបស់បុគ្គល ។

ឈុនលី ៖ អ៊ំចង់ធ្វើឲ្យគាត់អស់កំហឹង ដូចថាអ្នកដែលគាត់ខឹងអីចឹង អ៊ំមានចិត្តចង់និយាយប្រាប់គាត់?

វ៉េន ៖ ខ្ញុំនិយាយដែរទៅ វែងឆ្ងាយណាស់បើរឿងនយោបាយក៏ខ្ញុំមិនអាចនិយាយបានដែរ ។

ឈុនលី ៖ ម៉េចទៅ?

វ៉េន ៖ ព្រោះអានឹងវាផ្ទៃក្នុងវាប៉ះពាល់សម្តេចនាយករដ្ឋមន្ត្រី ចុះជំនាន់នឹងគាត់មិនធ្វើខ្មែរក្រហម ។

ឈុនលី ៖ អ៊ំស្គាល់គាត់ដែរ?

វ៉េន ៖ ខ្ញុំអត់ស្គាល់ទេ ប៉ុនបណ្តាញគាត់ ។ ធម្មតាមេៗលាក់ម៉េចចិត្តអ្នកណាធ្វើអីៗ គាត់តស៊ូដែរនឹងសម្តេចនាយករដ្ឋមន្ត្រី ។

ឈុនលី ៖ តែគាត់នៅខាងណា?

វ៉េន ៖ គាត់នៅភូមិភាគ នៅខាងកំពង់ចាម ព្រោះតំបន់វាខុសគ្នា ហើយខ្ញុំនៅខាងភូមិភាគពិសេស ចុះយើងមិនមែនដើរម៉ាប្រទេស មិនមែនយើងដើរទាំងអស់ ប៉ុនកងពលខុសៗគ្នា ប៉ុនគ្រាន់ដឹងថាកងពលនេះឈ្មោះនេះៗ ហើយគាត់ពួកម៉ាក់គាត់មកនៅភូមិដូងដែរ ។

ឈុនលី ៖ អ្នកណាគេ?

វ៉េន ៖ គាព្រួញៗនៅសិល្បៈ នឹងពួកម៉ានាយករដ្ឋមន្ត្រីដែរ ពេលដែលគាត់មកនេះ ជួបគ្នាដែរតើ ។

ឈុនលី ៖ គាព្រួញនឹងកាលពីមុនគាត់ធ្វើអី?

វ៉ន ៖ គាត់ទ័ពដែរ ទ័ពខ្មែរក្រហមដូចគ្នាទាំងអស់ ។ ប៉ុនដល់គាត់ឃើញប៉ុលពតធ្វើសម័យ៣ឆ្នាំនឹងខ្ទាំង បានគាត់ត្រឡប់ផ្នែកទៅរកវៀតណាមដើម្បីឲ្យជួយ ។

ឈុនលី ៖ តាព្រញ?

វ៉ន ៖ ហ៊ឺ! សម្តេចនាយករដ្ឋមន្ត្រី នឹងយើងនិយាយប្រវត្តិដើម គាត់ផ្តាច់ខ្លួនមុនខ្ញុំ គាត់មកនេះគាត់ថាគាត់ផ្តាច់ខ្លួនមុន ពួកខ្ញុំផ្តាច់ក្រោយគាត់ ។ ប៉ុនកាលនឹងសុទ្ធតែអ្នកផ្តាច់ខ្លួនដូចគ្នា ។

ឈុនលី ៖ គាត់ផ្តាច់ខ្លួនពេលណា?

វ៉ន ៖ គាត់ផ្តាច់ខ្លួន៧៩អីតាំងពី អឺ!យើងថាការពិតតាំងពី៧៨ប្រវត្តិរត់ទៅវៀតណាមនោះ ។

ឈុនលី ៖ បើគិតទៅឋានៈគាត់ឋានៈណា?

វ៉ន ៖ ឋានៈពីដើមកងពល ។

ឈុនលី ៖ ប្រធានកងពល?

វ៉ន ៖ អឺ! ប្រធានកងពល ចាប់ច្រើនប៉ុលពតវៃចោលអស់ច្រើន សោ ភឹម, ចេង អន, វ៉ន វេតសុទ្ធតែអ្នកធំៗ ។ បានថារឿងនយោបាយកុំដឹងច្រើនពេកទៅ និយាយឲ្យខ្លីៗបានហើយព្រោះដំណាក់កាលឥឡូវវាឆ្ងងផុតអស់ហើយ ។ គេនិយាយដំណាក់កាលអភិវឌ្ឍប្រទេសជាតិ

ឈុនលី ៖ ដូចជាអស់អីសួរ ។

វ៉ន ៖ ហ៊ឺ! មានរឿងអីចង់សួរអីទៀត អត់អីទេខ្ញុំ ។

ឈុនលី ៖ អ៊ំមានលេខទូរស័ព្ទទេ?

វ៉ន ៖ មានតែលេខកូន ខ្ញុំអត់ប្រើទេ ។

ឈុនលី ៖ បើខ្ញុំចង់call មកសួរបន្ថែមកន្លែងណាខ្ញុំអត់យល់?

វ៉ន ៖ បាន ។

ឈុនលី ៖ អាចcallមកលេខបង?

កូន ៖ ចា៎!

ឈុនលី ៖ អ៊ំមាននៅសល់រូបថតចាស់ៗទេ?

វ៉ន ៖ រូបថតខ្ញុំមាន ។

ឈុនលី ៖ ជំនាន់ណា?

វ៉ន ៖ ជំនាន់ពីមុនអត់មានបានថតទេ ។

ឈុនលី ៖ រូបថតចាស់នឹងខ្ទង់ឆ្នាំណា?

វ៉ន ៖ ឆ្នាំ... ។

ឈុនលី ៖ ខ្ទង់ឆ្នាំ៨០ជាងអីទេ?

វ៉ែន ៖ បាទ! មាន ។

ឈុនលី ៖ ខ្ញុំចង់សុំទៅថតចម្លងហើយយកទៅឲ្យអ៊ីវិញ ។

វ៉ែន ៖ បាទ! មាននៅផ្ទះលិចនោះ ។ ពីដើមផ្ទះខ្ញុំនៅនេះទេ ដល់មិនទាន់ផ្តាច់ខ្លួនគេបង្កើតនៅភូមិនេះ គេបង្កើតពាណិជ្ជកម្មរកស៊ី បង្កើតក្រុមហ៊ុនទុនខ្ញុំដាក់ធំជាងគេៗដាក់៥០០-១០០០-២០០០ ខ្ញុំដាក់៥០០០បាត ។

ឈុនលី ៖ ពេលនឹងផ្តាច់ខ្លួននៅ?

វ៉ែន ៖ នៅទេ បង្កើតក្រុមហ៊ុនរកស៊ីនឹង អត់ទាន់ផ្តាច់ខ្លួនទេ

ឈុនលី ៖ រកស៊ីអីគេ ពោត?

វ៉ែន ៖ អត់ទេ បង្កើតពាណិជ្ជកម្ម លក់ចាប់ហួយម៉ាភូមិនឹង គេឲ្យរកស៊ីរួមគ្នា ។

ឈុនលី ៖ លក់ឲ្យខាងណា?

វ៉ែន ៖ លក់ឲ្យប្រជាជននឹង លក់ឲ្យខ្លួនឯង ទិញខ្លួនឯង ។

ឈុនលី ៖ កាលនឹងរកស៊ីធូរធារទេ?

វ៉ែន ៖ ធូរចុះខ្ញុំ ។

ឈុនលី ៖ រកគោផង រកអ៊ីវ៉ាន់ផង?

វ៉ែន ៖ រកអីវ៉ាន់នឹងគេចាត់តាំងប្រធានគ្រប់គ្រងពាណិជ្ជនឹងអ្នកផ្សេង ប៉ុន្តែគ្រាន់ថាខ្ញុំទុនធំជាងគេចែកម្តងៗគេបាន៥០០ ខ្ញុំបានជិត២០០០ ចុះយើងដើមធំ ។

ឈុនលី ៖ ម៉ាខែចែកម្តង?

វ៉ែន ៖ ហ្នឹងហើយម៉ាខែ ។

ឈុនលី ៖ រូបថតមានច្រើនទេនៅផ្ទះ?

វ៉ែន ៖ នៅផ្ទះលិច ។

ឈុនលី ៖ មានច្រើនទេ អាឆ្នាំ៨០ជាងមានប៉ុន្មានសន្លឹក?

វ៉ែន ៖ រូបថតខ្ញុំមានច្រើនដែរ ខ្ញុំទៅលេងអង្គរវត្តលេងអី ។

ឈុនលី ៖ ៨០ជាង?

វ៉ែន ៖ បាទ! សម័យសង្គ្រាម៥ឆ្នាំ ខ្ញុំតស៊ូបានច្រើនមែនទែន បើនិយាយពីលន់ នល់ ខ្ញុំទៅលេងយៀកកុង ខ្ញុំទៅវៃដែរខាងទន្លេមេគង្គ ហើយបានភ្ជាប់មកទន្លេបាសាក់ មកផ្លូវជាតិលេខ១ ផ្លូវជាតិលេខ២ ផ្លូវជាតិលេខ៣ ថ្នល់រទេះភ្លើង ផ្លូវជាតិលេខ៤ឆ្លងមកវៃដល់ថ្នល់ជាតិលេខ៥ វៃជិតភ្នំពេញ....ជុំវិញភ្នំពេញ ។

ឈុនលី ៖ អ៊ំដឹងរឿងតាម៉ុក ហើយនឹងតាប៉ុលពត ឈ្លោះគ្នា អ៊ី!តាសុន សេន? ពេលដែលតាសុន សេន ហើយនឹងតាប៉ុលពត គាត់ប្រឆាំងគ្នា អ៊ំដឹងរឿងរ៉ាវអីខ្លះ?

វ៉េន ៖ គ្មានអីទេ អានឹងធម្មតា របៀបគេហៅថាលាក់ម្នាក់ៗ ចុះបើមិនលាក់ ឧទាហរណ៍ថាសុន សេន គាត់នៅខាងសំពៅលូន ឃើញទេគាត់ក្ដាប់ពាអង្គភាពនៅខាងម៉ាឡៃក៏គាត់ សំពៅលូនក៏គាត់ខាងប៉ៃលិនក៏គាត់ ប៉ុនដល់មានរឿង សុន សេននេះអត់រាយការណ៍ឲ្យប៉ុលពត។ ចង់ដោះស្រាយខ្លួនឯង។ ដល់ម៉ាឡៃ និងប៉ៃលិននឹងផ្ដាច់ខ្លួន បានប៉ុលពតក្ដាក់ខ្លួន ដល់អស់កម្លាំងពីដៃៗ ។

ឈុនលី ៖ បានន័យថាសុន សេនគាត់ដឹង?

វ៉េន ៖ គាត់ដឹងតែខ្លួនគាត់ គាត់ធ្វើអីតែខ្លួនគាត់ គាត់អត់ឲ្យថ្លៃខ្លួន។ ដល់ពេលអីចឹងប៉ុលពត ចាប់អារម្មណ៍ ប៉ុលពតថា សុន សេន នេះគំនិតមិនល្អហើយ។ ហើយដល់ សុន សេន មើលទៅ ប៉ុលពតថាមិនស្រួល។ អីចឹងហើយបានបូរាណគេនិយាយ គេថាដូចបុរាណៗថា ព្រះពុទ្ធទំនាយក៏ថាបាន ហើយពុស្សភាសិតក៏បាន ដូចពាក្យចាស់គេថា កាំបិតចិតដងឯង។

ឈុនលី ៖ ផ្ដាច់ខ្លួនដោយសារលោក សុខ ភាព?

វ៉េន ៖ បាទ! មកពីអាពីរនឹង ស្មានតែធ្វើទៅគេនៅគាំទ្រ។

ឈុនលី ៖ តើតាអៀង សារី ដឹងទេ?

វ៉េន ៖ អត់ដឹង តាអៀង សារីក៏ចង់កុនៗរបស់ប៉ុលពត ប៉ុនគាត់រវាស់ គាត់សុំឈប់។

ឈុនលី ៖ គាត់ឈប់ពេលណា?

វ៉េន ៖ ឈប់អាពេល......ហ្នឹងប៉ុលពតចោទថាអ៊ំអៀង សារីនេះបំផុសឲ្យពួកនេះរើ។

ឈុនលី ៖ តែតាមការពិតអត់មានទេ?

វ៉េន ៖ អត់មានទេ។ ប៉ុនដល់ផ្ដាច់ខ្លួនហើយ បងភាពនេះ សុំឲ្យអ៊ំអៀង សារីចូលមកវិញ។ អ៊ំអៀង សារីគាត់ចេញពីនេះខ្លាចប៉ុលពត ទៅលាក់ខ្លួននៅថៃ។

ឈុនលី ៖ កាលពេលនឹងគាត់ធ្វើអី?

វ៉េន ៖ គាត់អត់ធ្វើអី...ឈប់ឲ្យភាពនឹងដោះស្រាយខ្លួនឯងទៅជាមួយរដ្ឋ។

ឈុនលី ៖ តាសុខ ភាពនឹង គាត់ដឹកនាំអត់មានសួរយោបល់តាអៀង សារីដែរ?

វ៉េន ៖ អត់ទេ គ្មានបានអីសួរ គាត់ម៉េចសួរ បើអ៊ំអៀង សារី និងសាខាគេថ្នាក់ដឹកនាំខ្ពស់ៗគេជាមួយគ្នា គាត់អត់ទុកចិត្តដែរ។

ឈុនលី ៖ តាសុខ ភាពអត់ទុកចិត្ត?

វ៉េន ៖ បាទ! ប៉ុនគ្រាន់ដឹងថាអ៊ំអៀង សារី គាត់ចាប់ផ្ដើមដកខ្លួនហើយ។

ឈុនលី ៖ បើគិតទៅអ៊ំអៀងសារី គាត់ចាប់ផ្ដើមដកពេលណាទៅ?

វ៉េន ៖ ពេល ពិបាកថាដែរ ពួកនឹងវាទាក់ទិនគ្នាពីនេះពីនោះរយីរយោងដូចសម្ងកំពីស ភ្លាប់រឿង ច្រើនពេក ។ អីចឹងបានថាបណ្ដាយវាច្រើនណាស់ ច្រើនសន្ធាក់ គេច្រើនរយៈ ចុះដូចគេ ហៅថាយើងមុខ២ ។ ចុះខ្ញុំរកស៊ីគោ ខ្ញុំដើរទៅទិញគោដល់ភ្នំព្រឹកអីចឹង... ដូនកាលខាងនោះ គេបញ្ជូនទ័ពមកវ៉ៃម៉ាឡៃ ។ គេចោទម៉ាឡៃនេះថាក្បត់ហើយ បងសាម៉ីនគាត់ហៅទៅប្រាប់ ឥឡូវអ្នកឯងទៅពិនិត្យមើលផង ទៅក្រឡេកមើលខាងគីឡូ៩នឹង តើសកម្មភាពគេម៉េចខ្លះ ។ ហើយខ្ញុំអ្នករកស៊ីគោ ខ្ញុំធ្វើដើរទៅទិញគោ ប៉ុនកាលពិតខ្ញុំក្រឡេកភ្នែក ។ ដល់គ្រាន់តែខ្ញុំទៅ ដល់ព្រំប្រទល់ឃើញឡានដឹកទ័ពមកពឡាន មកចុះនៅព្រំប្រទល់នឹង ។ ខ្ញុំចាប់អារម្មណ៍ ខ្ញុំ រវាសណាស់ ខ្ញុំចាប់អារម្មណ៍សភាពការអត់ស្រួលទេ ។ ខ្ញុំដើរទៅទៀតឃើញឡានម៉ាគ្រឿង នឹង អត់មានទ័ពទេ ចងមេក្រូដាប់នឹងដំបូលឡាន អាមេក្រូនឹងចាំស្រែកឃោសនាហើយ ខ្ញុំ ដឹង ។ ដល់ខ្ញុំទៅជិតដល់រោងយាមខាងនោះឃើញទ័ពគេដើរប៉ុន្មានកង អានឹងគេដើរ១០នាក់ ជាង អាជិះឡានមកចុះមុខ អ្នកដើរៗ ។ ដល់ឃើញអាដើរវាចំអានៅជាមួយខ្ញុំពី៧៩ វា ក្មេងវានៅកុមារប៉ុនវានៅទ័ពជាមួយខ្ញុំ វានៅក្នុងក្រុមខ្ញុំនឹង ឈ្មោះវាអាចាន់ៗ វាក្រឡេក ឃើញខ្ញុំវាស្គាល់ ថាបង ។ ចុះឯងទៅណា? អានឹងបានទំនាក់ទំនងគ្នា បានខ្ញុំសួរថា ចាន់ ឯងដឹងរឿងទេ ចុះវាធ្វើមេហើយ វាឡើងធ្វើមេកងវរសេនាតូច វាក្ដាប់ម៉ាកងធំហើយ ។ មកនឹងខ្ញុំថា ឯងដឹងរឿងនឹង ប៉ុននិយាយតិចៗអត់ឲ្យអ្នកណាឮ ។ ហ៊ើ!ខ្ញុំអត់ដឹងទេ ប៉ុនគេ បញ្ជូនមក ។ ខ្ញុំថាប្រយ័ត្នទៅប្រយ័ត្ន ខ្លាំងវ៉ៃមិនបាន វ៉ៃគ្នាឯង ឯងមើលមែនទែន តាម ដានឲ្យច្បាស់ម៉េចៗឯងសួរអញ ព្រោះនៅនេះអញក្ដាប់បានរឿងច្រើន ធ្វើម៉េចរកគ្នា ឈ្មោះ ឲ្យមកឈ្មោះគ្នា ។ កុំភ័យបងឯងចាំមើល ខ្ញុំទៅសិន ។ ឯងសុទ្ធតែគ្នាឯង ឯងមើល យើងមានអ្នកមកពីណា គ្មានប៉ាវ៉ាណាគេ ។ សុន សេន រាយការណ៍ប្រាប់ទ័ពខាងនោះថា ម៉ាឡៃពួកប៉ាវ៉ាចូលពេញហើយ ចោទរាយការណ៍ប្រាប់ទ័ពខាងនោះវ៉ៃ ទ័ពខាងនោះមកវ៉ៃ មកដល់ដាក់ម៉ីង ។

ឈុនលី ៖ ដោយសារតា សុន សេន គាត់ខឹងរឿងអត់បង្កើតសហករណ៍?

វ៉េន ៖ អត់បង្កើតអី ប្រឆាំងរឿងរទេះគោនឹង គេផ្ដាច់ខ្លួននឹង បានចោទថាប៉ាវ៉ានឹង ។

ឈុនលី ៖ គោលបំណងរបស់គាត់ចង់បង្កើតសហករណ៍ បានប្រមូលរទេះគោ?

វ៉េន ៖ អត់បង្កើតទេ គ្មានបង្កើតអីវា គេដកយកទៅទុកនៅខ្លួនគេ ។

ឈុនលី ៖ ចុះអត់ឲ្យរកស៊ី?

វ៉េន ៖ ឲ្យយើងស៊ីតែរបបគេឲ្យមក ឧបមាថាអង្ករគេចែកឲ្យមកប៉ុន្មានស៊ីប៉ុននឹងទៅ ។

ឈុនលី ៖ តែអានឹងវាដាររបៀបសហករណ៍ដែរ?

វ៉ែន ៖ មិនមែនទេ គេលេងហើយ ស៊ីបាយឯកជន ។

ឈុនលី ៖ គិតទៅឲ្យរបប តែអត់បង្កើតសហករណ៍?

វ៉ែន ៖ អត់បង្កើតទេ យើងធ្វើអីធ្វើទៅ ។

ឈុនលី ៖ ហើយពេលនឹងម៉េចទៅ?

វ៉ែន ៖ ដល់ហើយវាដើរមក ព្រោះកុងត្រូលវាមាន២រោងយាម ៗខាងម៉ាឡៃចេះទៅ រោងយាមខាងសំពៅលូនចេះមក វាខុសត្រូវដីប្រហែលម៉ាគីឡូ ហើយដល់គេខាងសំពៅលូនគេមកដល់កុងត្រូលខាងម៉ាឡៃនេះវាអត់មានឃើញប៉ាវ៉ា ។ ដល់គេថា ចុះរាយការណ៍ទៅប្រាប់វាថាសុទ្ធតែប៉ាវ៉ា ដល់អត់ឃើញប៉ាវ៉ា ក៏វាអត់មានបាញ់គ្នានអីដោះស្រាយគ្នា ចចារគ្នា ។

ឈុនលី ៖ ដល់ហើយបានផ្តាច់ខ្លួនបណ្តោយ?

វ៉ែន ៖ បាទ! ផ្តាច់ខ្លួនដល់យើងដឹងៗមានអីលើកទ័ពពីនេះទៅ ។

ឈុនលី ៖ បានវ៉ៃម៉ាសារទៀត?

វ៉ែន ៖ អត់ទេ អត់បានវ៉ៃទេ ចេញពីប៉ៃលិននឹងមកទប់គ្នា ពួកនឹងដាក់អាវុធទៅ ពួកសុន សេននោះ ។ ដល់ដាក់អាវុធទៅ សុន សេន គាត់រត់ ។ ហើយយើងគ្មានធ្វើអី យើងគ្រាន់ឲ្យសុន សេនចុះ ។

«ចប់»